**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១១២៩....សហវ.ប្រក.[illegible]

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពី កិច្ចបញ្ជិកាគណនេយ្យនៃគណនីត្រួតសង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួលមាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃគណនីត្រូវសង ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**ប្រការ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៣ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# គោលការណ៍ណែនាំ

# ស្តីពី

# កិច្ចបញ្ជិកាគណនេយ្យនៃគណនីត្រូវសង

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# មាតិកា


| | | ទំព័រ |
|---|---|---|
| **ជំពូកទី១** | **បទប្បញ្ញត្តិទូទៅ** | ១ |
| ១. | គោលបំណង | ១ |
| ២. | វិសាលភាព | ១ |
| ៣. | និយមន័យ | ១ |
| **ជំពូកទី២** | **ការទទួលស្គាល់និងការវាស់វែងចំណាយ** | ៤ |
| | **ផ្នែកទី១÷ ការទទួលស្គាល់ចំណាយ** | ៤ |
| ១. | លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយបន្ទុកបុគ្គលិក | ៤ |
| ២. | លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយពីការទិញទំនិញ និងសេវាកម្ម | ៦ |
| ៣. | លក្ខខណ្ឌនៃការទទួលស្គាល់បន្ទុកហិរញ្ញវត្ថុ | ៧ |
| ៤. | លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយមូលធន | ៨ |
| ៥. | លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយពីការផ្ទេរ | ៩ |
| | **ផ្នែកទី២÷ ការវាស់វែងចំណាយ** | ១០ |
| **ជំពូកទី៣** | **ចំណាយបង្ករនិងបំណុលជាយថាហេតុ** | ១១ |
| ១. | ចំណាយបង្ករ | ១១ |
| ២. | ការទទួលស្គាល់បំណុល | ១១ |
| ៣. | ការទទួលស្គាល់បំណុលជាយថាហេតុ | ១២ |
| ៤. | ចំណាយពន្យារ | ១៣ |
| **ជំពូកទី៤** | **គណនេយ្យកម្មលើការទទួលស្គាល់ចំណាយ** | ១៤ |
| ១. | ចំណាយបន្ទុកបុគ្គលិក | ១៥ |
| ២. | ចំណាយពីការទិញទំនិញ និងសេវាកម្ម | ១៦ |
| ៣. | បន្ទុកហិរញ្ញវត្ថុ | ១៧ |
| ៤. | ចំណាយមូលធន | ១៩ |
| ៥. | ចំណាយពីការផ្ទេរ | ២០ |
| ៦. | សំណេសចំណាយ | ២១ |
| ៧. | ការបង្វិលសងពន្ធលើតម្លៃបន្ថែម | ២២ |
| ៨. | ការកែតម្រូវក្រោយពីការទទួលស្គាល់ចំណាយ | ២៣ |
| **ជំពូកទី៥** | **ការឈប់ទទួលស្គាល់គណនីត្រូវសង** | ២៤ |
| ១. | លក្ខខណ្ឌនៃការឈប់ទទួលស្គាល់គណនីត្រូវសង | ២៤ |

២. គណនេយ្យកម្មនៃការឈប់ទទួលស្គាល់គណនីត្រូវសង ២៤

**ជំពូកទី៦ រំហូរដំណើរការនិងការរាយការណ៍នៃគណនីត្រូវសង ២៧**

១. ភាគីពាក់ព័ន្ធ ២៧

២. រំហូរដំណើរការ ២៨

៣. ឯកសារតម្រូវសម្រាប់ការទទួលស្គាល់ចំណាយ ២៨

៤. សមតុល្យដើមគ្រានៃគណនីត្រូវសង ២៨

៥. ការរាយការណ៍គណនីត្រូវសង ២៨

**ឧបសម្ព័ន្ធ៖**

ឧបសម្ព័ន្ធ១ ការផ្គូផ្គងចំណាយជាមួយនឹងលក្ខខណ្ឌតម្រូវនៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជានិងអន្តរជាតិ ៣០

ឧបសម្ព័ន្ធ២ គំរូរបាយការណ៍នៃគណនីត្រូវសង ៣៥

ឧបសម្ព័ន្ធ៣ គំរូរបាយការណ៍រួមនៃគណនីត្រូវសង ៣៦

# ជំពូកទី១

# បទប្បញ្ញត្តិទូទៅ

## ១. គោលបំណង

គោលការណ៍ណែនាំនេះ បានកំណត់អំពីលក្ខខណ្ឌនៃការទទួលស្គាល់ ការវាស់វែង និងផ្តល់នូវការណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃចំណាយ និងគណនីត្រូវសង ឱ្យបានត្រឹមត្រូវ ទៅតាមស្តង់ដាគណនេយ្យសាធារណៈ ដើម្បីឱ្យការរាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវនៃប្រតិបត្តិការហិរញ្ញវត្ថុ(របាយការណ៍លទ្ធផល) និងស្ថានភាពហិរញ្ញវត្ថុ(តារាងតុល្យការ) របស់ស្ថាប័នសាធារណៈ។

គោលការណ៍ណែនាំនេះ ក៏ជាផ្នែកមួយនៃផែនការផ្លាស់ប្តូរប្រព័ន្ធគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់ ទៅប្រព័ន្ធគណនេយ្យសាធារណៈមូលដ្ឋានសាច់ប្រាក់កែសម្រួល ស្របតាមយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា២០២១-២០៣១។

គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយស្របតាមស្តង់ដាគណនេយ្យសាធារណៈកម្ពុជា និងស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិដែលពាក់ព័ន្ធនានា។

## ២. វិសាលភាព

គោលការណ៍ណែនាំនេះ អនុវត្តចំពោះស្ថាប័នសាធារណៈ។ គោលការណ៍ណែនាំនេះ ត្រូវយកទៅអនុវត្តចំពោះលក្ខខណ្ឌនៃការទទួលស្គាល់ និងកិច្ចបញ្ជិកាគណនេយ្យនៃកិច្ចប្រតិបត្តិការចំណាយ និងចំណាយបង្គរ ទៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល សម្រាប់ស្ថាប័នសាធារណៈដែលពាក់ព័ន្ធនឹងការងារមួយចំនួនដូចខាងក្រោម÷

ក. ចំណាយបន្ទុកបុគ្គលិក

ខ. ចំណាយការទិញទំនិញ និងសេវាកម្ម

គ. បន្ទុកហិរញ្ញវត្ថុ

ឃ. ចំណាយមូលធន

ង. ចំណាយលើការផ្ទេរ

ច. សំណេសចំណាយ

ឆ. ការបង្វិលសងពន្ធលើតម្លៃបន្ថែម

ជ. ការកែតម្រូវកិច្ចបញ្ជិកាគណនេយ្យ ក្រោយការទទួលស្គាល់ចំណាយ។

គោលការណ៍ណែនាំនេះ មិនរាប់បញ្ចូលពីនីតិវិធីក្នុងការទទួលស្គាល់ និងការធ្វើកិច្ចបញ្ជិកាគណនេយ្យនៃប្រតិបត្តិការចំណេញ ខាត ពីអត្រាប្តូរប្រាក់ទេ ដែលកិច្ចការនេះនឹងត្រូវដាក់បង្ហាញក្នុងគោលការណ៍ណែនាំផ្សេងទៀត។

## ៣. និយមន័យ

ពាក្យឬវាក្យស័ព្ទដែលប្រើប្រាស់នៅក្នុងគោលការណ៍ណែនាំនេះ ត្រូវបានកំណត់ដូចខាងក្រោម÷

**កិច្ចសន្យា** សំដៅដល់កិច្ចព្រមព្រៀងរវាងភាគីពីរ ឬ ច្រើនដែលបង្កើតសិទ្ធិនិងកាតព្វកិច្ចដែលត្រូវអនុវត្ត។

**ការទូទាត់** សំដៅដល់ការបំពេញកាតព្វកិច្ចដោយផ្នែក ឬ ទាំងស្រុង តាមរយៈការដោះស្រាយបំណុលរបស់ខ្លួនក្នុង

ទម្រង់នៃការបង់ប្រាក់ ដោយយោងតាមវិក្កយបត្រដែលបានអនុម័តយល់ព្រមរួចហើយ។

**គណនីត្រូវសង** សំដៅដល់ចំនួនទឹកប្រាក់ដែលស្ថាប័នសាធារណៈជំពាក់អ្នកផ្គត់ផ្គង់សម្រាប់ការទិញទំនិញនិងសេវាកម្មដោយមិនទាន់បានទូទាត់សាច់ប្រាក់។ គណនីត្រូវសង ឆ្លុះបញ្ចាំងអំពីការទទួលខុសត្រូវរបស់ស្ថាប័នសាធារណៈក្នុងការទូទាត់បំណុលទៅអ្នកផ្គត់ផ្គង់។

**ចំណាយ** សំដៅដល់ប្រតិបត្តិការដែលនាំឱ្យមានការថយចុះនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងអំឡុងពេលរាយការណ៍ ជាទម្រង់នៃការហូរចេញ ឬ ការប្រើប្រាស់ទ្រព្យសកម្ម ឬ ការកើនឡើងនៃបំណុលដែលនាំឱ្យមានការថយចុះនៃទ្រព្យសកម្មសុទ្ធ ក្រៅពីទ្រព្យសកម្មដែលពាក់ព័ន្ធទៅនឹងការបែងចែកទៅឱ្យម្ចាស់ភាគលាភ។

**ចំណាយទិញទ្រព្យសកម្ម** សំដៅដល់ការចំណាយសាច់ប្រាក់សម្រាប់ទិញទ្រព្យសកម្ម(ចំណាយមូលធន) ឬ ជាការចំណាយសាច់ប្រាក់សម្រាប់គោលបំណងប្រតិបត្តិការ(ចំណាយប្រតិបត្តិការ)។ ដោយសារពាក្យ "ចំណាយ" និង "ចំណាយទិញទ្រព្យសកម្ម" អាចមានភាពខុសគ្នាក្នុងទិដ្ឋភាពនៃវិធានគណនេយ្យ ជាពិសេសទៅលើការប្រើប្រាស់ពាក្យ "ចំណាយទិញទ្រព្យសកម្ម"។ "ចំណាយទិញទ្រព្យសកម្ម" អាចកត់ត្រាជាចំណាយមូលធន(ឧទាហរណ៍ការទិញរថយន្ត) ជាទូទៅមិនបណ្តាលឱ្យមានការចុះបញ្ជីជាចំណាយទាំងអស់ភ្លាមៗទេ ដោយគ្រាន់តែទទួលស្គាល់ជាចំណាយខ្លះតាមវិធីរំលស់បង្គរ ដែលនឹងកើតឡើងនៅពេលក្រោយ បន្ទាប់ពីទ្រព្យសកម្មត្រូវបានទទួលស្គាល់ និងប្រើប្រាស់។ ចំពោះពាក្យ "ចំណាយ" សំដៅដល់ចំណាយចរន្ត(ប្រតិបត្តិការ) អាចធ្វើការចុះបញ្ជីជាចំណាយទាំងអស់ភ្លាមៗតែម្តង។

**តម្លៃសមស្រប** សំដៅដល់ចំនួនទឹកប្រាក់ដែលទ្រព្យសកម្មមួយអាចត្រូវបានយកមកដោះដូរ ឬ បំណុលមួយត្រូវបានទូទាត់សង រវាងភាគីស្ម័គ្រចិត្តនិងមានចំណេះដឹងនៅក្នុងប្រតិបត្តិការបើកចំហ។ ប្រតិបត្តិការបើកចំហសំដៅដល់សកម្មភាព ទិញ-លក់ មានការព្រមព្រៀងគ្នាតាមតម្លៃទីផ្សារ។

**បំណុល** សំដៅដល់កាតព្វកិច្ចបច្ចុប្បន្នរបស់ស្ថាប័នសាធារណៈដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាល ដែលការទូទាត់ត្រូវបានរំពឹងថាកើតមានតាមរយៈរំហូរចេញនៃធនធានរបស់ស្ថាប័នសាធារណៈ។

**បំណុលជាយថាហេតុ(Contingent liability)** សំដៅដល់បំណុលជាសក្តានុពល ដែលអាចប្រែជាបំណុលពិតជាក់ស្តែងប្រសិនព្រឹត្តិការណ៍ពិតកើតឡើង។

**បញ្ជាទិញ** សំដៅដល់លិខិតបញ្ជាទិញផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងការផ្តល់ទំនិញ និង/ឬ សេវាដោយកំណត់ពីតម្លៃ កន្លែង ពេលវេលា និងលក្ខខណ្ឌជាក់លាក់។

**ប្រតិបត្តិការដោះដូរ** សំដៅដល់ប្រតិបត្តិការមួយ ដែលស្ថាប័នសាធារណៈទទួលបានទ្រព្យសកម្ម ឬ សេវា ឬ បានទូទាត់សងបំណុល និងផ្តល់តម្លៃតបស្នងប្រហាក់ប្រហែលដោយផ្ទាល់(ជាចម្បងក្នុងទម្រង់ជាទំនិញសេវា ឬ ការប្រើប្រាស់ទ្រព្យសកម្ម) ទៅឱ្យភាគីផ្សេងទៀតក្នុងការដោះដូរ។ ឧទាហរណ៍ ក្រសួង ក. បានទូទាត់សាច់ប្រាក់ចំនួន ១ ០០០ ០០០រៀល ពីការទទួលបានទំនិញ និង សេវាកម្មពីអ្នកផ្គត់ផ្គង់។

**ប្រតិបត្តិការមិនដោះដូរ** សំដៅដល់ប្រតិបត្តិការក្រៅពីប្រតិបត្តិការដោះដូរ។ ក្នុងប្រតិបត្តិការមិនដោះដូរ ស្ថាប័នសាធារណៈមួយអាចទទួលបានតម្លៃពីស្ថាប័នមួយផ្សេងទៀត ដោយមិនផ្តល់តម្លៃប្រហាក់ប្រហែលដោយផ្ទាល់ណាមួយជាថ្នូរក្នុងការដោះដូរ ឬ ផ្តល់តម្លៃទៅឱ្យស្ថាប័នមួយផ្សេងទៀត ដែលមិនទទួលបានតម្លៃប្រហាក់ប្រហែលដោយផ្ទាល់

ណាមួយជាថ្នូរក្នុងការដោះដូរ។ ឧទាហរណ៍ ក្រសួង ក. បានឧបត្ថម្ភធនដើម្បីគាំទ្រដល់ការប្រព្រឹត្តទៅនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយពុំទទួលបានអ្វីតបស្នងវិញឡើយ។

**វិក្កយបត្រ** សំដៅដល់ឧបករណ៍ពាណិជ្ជកម្មដែលមិនអាចចរចារបាននិងចេញដោយអ្នកផ្គត់ផ្គង់និងបានកំណត់អត្តសញ្ញាណភាគីទិញ-លក់ ព្រមទាំងពិពណ៌នាអំពីបរិមាណ ទំនិញនិងសេវាកម្មដែលបានផ្តល់ជូន និងបង្ហាញកាលបរិច្ឆេទនៃការផ្គត់ផ្គង់រួមគ្នាជាមួយនឹងតម្លៃ ការបញ្ចុះតម្លៃ(ប្រសិនបើមាន) និងបញ្ជាក់ពីលក្ខខណ្ឌបង់ប្រាក់។

**ស្ថាប័នសាធារណៈ** សំដៅដល់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**អ្នកផ្គត់ផ្គង់** សំដៅដល់ភាគីដែលបានចុះកិច្ចសន្យាជាមួយស្ថាប័នសាធារណៈដើម្បីផ្គត់ផ្គង់ទំនិញ ឬ សេវាកម្ម។

## ជំពូកទី២

## ការទទួលស្គាល់និងការវាស់វែងចំណាយ

ជាកិច្ចការចាំបាច់ និងមានសារៈសំខាន់ ក្នុងការទទួលស្គាល់និងការវាស់វែងចំណាយឱ្យបានត្រឹមត្រូវនៅពេលដែលប្រតិបត្តិការចំណាយ ឬ ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានចំណាយកើតឡើង។ ចំណាយត្រូវទទួលស្គាល់ស្របតាមគោលការណ៍សំខាន់ៗ នៃគណនេយ្យមូលដ្ឋានបង្គរ ដែលលក្ខខណ្ឌតម្រូវនៃការទទួលស្គាល់មានកំណត់នៅក្នុងស្តង់ដាដែលពាក់ព័ន្ធ។ ជំពូកទី២នេះ ត្រូវបានបែងចែកជាពីរផ្នែក÷ ផ្នែកទី១ កំណត់ពីលក្ខខណ្ឌ និងពេលវេលានៃការទទួលស្គាល់សម្រាប់កិច្ចប្រតិបត្តិការចំណាយនីមួយៗ និងចំណាយលើការផ្ទេរធនធាន ឬ សេវាកម្ម ទៅស្ថាប័នសាធារណៈផ្សេងទៀត។ ផ្នែកទី២ កំណត់អំពីការវាស់វែងទ្រព្យសកម្មក្នុងតារាងតុល្យការ ដែលជាមូលដ្ឋានក្នុងការគណនាចំណាយបង្គរដូចជាការធ្វើរំលស់ដែលការវាស់វែងដំបូងត្រូវអនុលោមតាមតម្លៃសមស្រប និងការវាស់វែងបន្ទាប់ដោយយកតាមតម្លៃយោងគណនេយ្យ(ថ្លៃដើមដករំលស់បូកបន្ត) ក្នុងករណីថ្លៃដើមមិនអាចអនុវត្តបាន ការវាយតម្លៃទ្រព្យឡើងវិញជំនួសថ្លៃដើមអាចនឹងត្រូវប្រើប្រាស់។

## ផ្នែកទី១

## ការទទួលស្គាល់ចំណាយ

ស្ថាប័នសាធារណៈត្រូវទទួលស្គាល់ប្រតិបត្តិការចំណាយរួមមាន ចំណាយបន្ទុកបុគ្គលិក ចំណាយការទិញទំនិញ និងសេវាកម្ម បន្ទុកហិរញ្ញវត្ថុ ចំណាយមូលធន ចំណាយលើការផ្ទេរ នៅពេលដែលប្រតិបត្តិការចំណាយ ឬ ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការចំណាយកើតឡើង។ ចំណាយ គឺជាប្រតិបត្តិការដែលនាំឱ្យមានការថយចុះនៃអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងអំឡុងពេលរាយការណ៍ក្នុងទម្រង់នៃការហូរចេញ ឬ ការប្រើប្រាស់ទ្រព្យសកម្ម ឬ ការកើនឡើងនៃបំណុលដែលនាំឱ្យមានការថយចុះនៃទ្រព្យសកម្មសុទ្ធ ក្រៅពីទ្រព្យសកម្មដែលពាក់ព័ន្ធទៅនឹងការបែងចែកទៅឱ្យម្ចាស់ភាគលាភ។

ជាទូទៅក្នុងការអនុវត្តការទទួលស្គាល់ចំណាយ កើតឡើងតាមពីររបៀបគឺ÷

- **របៀបទីមួយៈ** ការទទួលស្គាល់ចំណាយនៅពេលដែលទំនិញ និង សេវាត្រូវបានទទួលនិងផ្តល់ឱ្យ
- **របៀបទីពីរៈ** ការទទួលស្គាល់ចំណាយនៅពេលដែលមានព្រឹត្តិការណ៍ធ្វើឱ្យស្ថានភាពតារាងតុល្យការរបស់ស្ថាប័នសាធារណៈចុះថយ ក្នុងនោះរួមមាន ការថយចុះទ្រព្យ ឬ ការកើនឡើងនូវបំណុល របស់អង្គភាពរាយការណ៍ជាដើម។ ជាក់ស្តែងក្នុងស្ថានភាពមួយចំនួនក៏អាចបណ្តាលឱ្យមានជាចំណាយផងដែរ មិនមែនដោយសារតែបំណុលត្រូវបានទទួលស្គាល់ និងទ្រព្យសកម្មមិនត្រូវបានទទួលស្គាល់នោះទេ ប៉ុន្តែគឺដោយសារទ្រព្យសកម្មដែលមានស្រាប់បានថយចុះតម្លៃ ដែលនាំឱ្យមានការទទួលស្គាល់ជាចំណាយ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពរាយការណ៍ស្តីពីការធ្លាក់ចុះតម្លៃតាមរយៈរំលស់។

### ១. លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយបន្ទុកបុគ្គលិក

ចំណាយបន្ទុកបុគ្គលិក កើតឡើងនៅពេលដែលស្ថាប័នសាធារណៈបានប្រើប្រាស់សេវាកម្មការងារដែលផ្តល់ជូនដោយមន្ត្រីបុគ្គលិករបស់ខ្លួន ចំណាយនោះរួមមាន អត្ថប្រយោជន៍រយៈពេលខ្លី អត្ថប្រយោជន៍រយៈពេលវែង និងប្រាក់បៀវត្សរបស់បុគ្គលិក។ ស្ថាប័នសាធារណៈ ត្រូវទទួលស្គាល់ចំណាយពាក់ព័ន្ធនឹងការចំណាយបន្ទុកបុគ្គលិក នៅពេល

បំពេញគ្រប់លក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷

ក. នៅពេលដែលបុគ្គលិកបានផ្តល់សេវា ជាថ្នូរដើម្បីទទួលបានអត្ថប្រយោជន៍ដែលនឹងត្រូវផ្តល់ជូនបុគ្គលិក នាពេលខាងមុខ និង

ខ. នៅពេលដែលស្ថាប័នសាធារណៈទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មដែលអាចកើតមានឡើងពីការផ្តល់សេវារបស់មន្ត្រី ឬ បុគ្គលិក។

ក្នុងការអនុវត្ត ចំណាយប្រាក់ខែសម្រាប់មន្ត្រីរាជការសាធារណៈ ត្រូវបានទទួលស្គាល់នៅពេលទទួលបានតារាងតួលេខចំណាយបន្ទុកបុគ្គលិកពីក្រសួងមុខងារសាធារណៈ។ ជាទូទៅ ប្រាក់ខែត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែដែលត្រូវបានបង់២ដង ក្នុងខែនីមួយៗ តាមការផ្ទេរចូលគណនីធនាគារ របស់មន្ត្រី បុគ្គលិកផ្ទាល់តែម្តង។ ចំពោះចំណាយលើការផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែ និងអត្ថប្រយោជន៍ផ្សេងទៀត ចំណាយដែលពាក់ព័ន្ធទៅនឹងការបង្វិលសងតាមប្រាក់គោលនយោបាយ(អាហារ និង ប្រាក់ហោប៉ៅ) នឹងត្រូវទទួលស្គាល់ជាចំណាយ នៅពេលដែលការស្នើសុំត្រូវបានទទួល និង អនុម័តដោយអាណាប័ក។

-លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ រួមមាន ខុទ្ទកាល័យព្រះបរមរាជវាំង ប្រាក់បំណាច់ ប្រធាន អនុប្រធាន និងសមាជិកស្ថាប័នកំពូល ប្រាក់បំណាច់ នាយករដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រី ប្រាក់បំណាច់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ប្រាក់បំណាច់អង្គទូត លាភការទីប្រឹក្សា លាភការបេសកជន លាភការអ្នកជំនួយការ ត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែ ដែលត្រូវបានបង់ ២ដង ក្នុងខែនីមួយៗ ត្រូវបានទទួលស្គាល់នៅពេលទទួលបានតារាងតួលេខចំណាយបន្ទុកបុគ្គលិកពីក្រសួងមុខងារសាធារណៈ។

-លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ រួមមាន បៀវត្សមូលដ្ឋាន ប្រាក់បំណាច់មុខងារត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែ ដែលសាច់ប្រាក់ត្រូវបានបង់ ២ដង ក្នុងខែនីមួយៗ។ ចំពោះ ប្រាក់បំណាច់ម៉ោងបន្ថែម ប្រាក់កំរៃគុរុកោសល្យ ប្រាក់បំប៉នជីវភាពពិសេស ប្រាក់បំណាច់ទទួលខុសត្រូវ និងប្រាក់បំណាច់ការងារធ្ងន់ និងប៉ះពាល់សុខភាព នឹងត្រូវទទួលស្គាល់ជាចំណាយ នៅពេលដែលការស្នើសុំត្រូវបានទទួល និង អនុម័តដោយអាណាប័ក។

-ប្រាក់បំណាច់ផ្សេងៗ រួមមាន រង្វាន់ប្រាក់បំណាច់បុគ្គលិកអង្គភាពផ្សេងៗ ប្រាក់បំណាច់គ្រូបង្គោលអង្គភាពផ្សេងៗ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបស់អង្គភាពដទៃទៀត ប្រាក់បំណាច់ផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែ ដែលសាច់ប្រាក់ត្រូវបានបង់២ដង ក្នុងខែនីមួយៗ ត្រូវបានទទួលស្គាល់នៅពេលទទួលបានតារាងតួលេខចំណាយបន្ទុកបុគ្គលិកពីក្រសួងមុខងារសាធារណៈ។

-ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ រួមមាន ឧបត្ថម្ភនិវត្តជន ប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ ត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែ ដែលសាច់ប្រាក់ត្រូវបានបង់ ២ដង ក្នុងខែនីមួយៗ។ ចំពោះការឧបត្ថម្ភមន្ត្រីមានជម្ងឺ អ្នកសម្រាលកូន មរណៈភាព គ្រោះថ្នាក់ក្នុងការងារនិងទព្វលភាព នឹងត្រូវទទួលស្គាល់ជាចំណាយ នៅពេលដែលការស្នើសុំត្រូវបានទទួល និង អនុម័តដោយអាណាប័ក។

-ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ រួមមាន កូនមានអាយុចាប់ពី២០ ឆ្នាំចុះ ប្រាក់បំណាច់អ្នកក្នុងបន្ទុក

ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ ប្រាក់វិភាជន៍សង្គមផ្សេងៗទៀតសម្រាប់គ្រួសារមន្ត្រីរាជការ ត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែ ដែលសាច់ប្រាក់ត្រូវបានបង់២ដង ក្នុងខែនីមួយៗ។ ត្រូវបានទទួលស្គាល់នៅពេលទទួលបានតារាងតួលេខចំណាយបន្ទុកបុគ្គលិកពីក្រសួងមុខងារសាធារណៈ។

-លាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានទទួលស្គាល់ជាចំណាយប្រចាំខែ ដែលសាច់ប្រាក់ត្រូវបានបង់២ដង ក្នុងខែនីមួយៗ។ ត្រូវបានទទួលស្គាល់នៅពេលទទួលបានតារាងតួលេខចំណាយបន្ទុកបុគ្គលិកពីក្រសួងមុខងារសាធារណៈ។

**២. លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយពីការទិញទំនិញ និងសេវាកម្ម**

ចំណាយកើតឡើងនៅពេលដែលរាជរដ្ឋាភិបាលទិញទំនិញ និងសេវាកម្មពីអ្នកផ្គត់ផ្គង់។ ស្ថាប័នសាធារណៈ ត្រូវទទួលស្គាល់ចំណាយពាក់ព័ន្ធនឹងការទិញទំនិញ និងសេវាកម្ម នៅពេលបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

ក. ទទួលបានទំនិញ ឬ សេវាកម្ម ណាមួយដោយផ្ទាល់ពីអ្នកផ្គត់ផ្គង់ជាថ្នូរ ដែលជាករណីមានការទិញ/លក់ ឬ

ខ. ករណីដែលមានការព្រមព្រៀងទូទាត់ប្រាក់ជាមួយស្ថាប័នផ្សេងទៀត ការទទួលស្គាល់ចំណាយនៅពេលកិច្ចព្រមព្រៀងត្រូវបានចុះហត្ថលេខាជាផ្លូវការ និងបានកំណត់ចំនួនទឹកប្រាក់ជាក់លាក់។

ជាក់ស្តែង ការអនុវត្តចំណាយលើការទិញទំនិញ និង សេវាកម្ម ត្រូវទទួលស្គាល់នៅពេលទំនិញ និង សេវាកម្មត្រូវបានផ្តល់ជូននិងទទួល។ នៅក្នុងកាលៈទេសៈមួយចំនួន ការចំណាយទិញទំនិញអាចនាំឱ្យមានសន្និធិមិនមែនទ្រព្យសកម្មរយៈពេលវែង ដែលគោលការណ៍ណែនាំនៃការគ្រប់គ្រងសន្និធិមិនមែនទ្រព្យសកម្មរយៈពេលវែង នឹងត្រូវរៀបចំនៅក្នុងគោលការណ៍ណែនាំដាច់ដោយឡែក។

-សម្ភារផ្គត់ផ្គង់ថែទាំ រួមមាន សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ ប្រេងឥន្ធនៈ និងប្រេងរំអិល សម្ភារផ្គត់ផ្គង់ថែទាំផ្សេងៗ ត្រូវទទួលស្គាល់ចំណាយនៅពេលទំនិញ និង សេវាកម្មត្រូវបានផ្តល់ជូន និងទទួល។

-សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល រួមមាន សម្ភារការិយាល័យ សៀវភៅមើល និងឯកសារ ការបោះពុម្ពសម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ ស្បៀង ចំណីសត្វ ពូជ និងកូនរុក្ខជាតិ ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និងជី ពូជសត្វ ឱសថ និងវត្ថុធាតុសម្រាប់បសុពេទ្យ ស្បៀងសម្រាប់រដ្ឋបាល ស្បៀងអាហារ និងផលិតផលកសិកម្មផ្សេងៗ ត្រូវទទួលស្គាល់ចំណាយនៅពេលទំនិញ និង សេវាកម្មត្រូវបានផ្តល់ជូននិងទទួល។

-សំលៀកបំពាក់ និងការតុបតែង រួមមាន ឯកសណ្ឋាន សំលៀកបំពាក់ការពារសុវត្ថិភាព មេដាយ សំលៀកបំពាក់ និងការតុបតែងផ្សេងៗ ត្រូវទទួលស្គាល់ចំណាយនៅពេលទំនិញ និង សេវាកម្មត្រូវបានផ្តល់ជូននិងទទួល។

-សម្ភារតូចតាច សង្ហារិម និងសម្ភារបរិក្ខារ រួមមាន សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា សង្ហារិម សម្ភារប្រើប្រាស់ សម្ភារ និងឧបករណ៍ដឹកជញ្ជូន សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា សម្ភារតូចតាច សង្ហារិម និងសម្ភារបរិក្ខារផ្សេងៗ ត្រូវទទួលស្គាល់ចំណាយនៅពេលទំនិញ និង សេវាកម្មត្រូវបានផ្តល់ជូននិងទទួល។

-ថាមពលនិងទឹក រួមមាន អគ្គិសនី ទឹក និងផ្សេងៗ ត្រូវទទួលស្គាល់ចំណាយនៅពេលទំនិញ និង សេវាកម្មត្រូវ

បានផ្តល់ជូននិងទទួល។

-សម្ភារបរិក្ខារថែទាំសុខភាព រួមមាន បំពង់ហ្គាសនិងអុកស៊ីសែន សម្ភារបរិក្ខារពេទ្យ សម្ភារបរិក្ខារថែទាំសុខភាពផ្សេងៗ ត្រូវទទួលស្គាល់ចំណាយនៅពេលទំនិញ និង សេវាកម្មត្រូវបានផ្តល់ជូននិងទទួល។

-កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស រួមមាន សេវាអនាម័យ សេវារដ្ឋបាល សេវាផ្សេងៗ ត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាជួល ទិញសេវាកម្មត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-ការជួលមធ្យោបាយដឹកជញ្ជូន រួមមាន ការជួលមធ្យោបាយដឹកជញ្ជូន និងការជួលមធ្យោបាយដឹកជញ្ជូនផ្សេងៗ ត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាជួល ទិញសេវាកម្មត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-ថ្លៃឈ្នួល និងបន្ទុក (អសង្ហារិម) ក្នុងនិងក្រៅប្រទេស រួមមាន ថ្លៃឈ្នួល និងបន្ទុក (អសង្ហារិម) ក្នុងប្រទេស និងក្រៅប្រទេស និងថ្លៃឈ្នួល និងបន្ទុក (អសង្ហារិម) ផ្សេងៗ ត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាជួល ទិញសេវាកម្មត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-សោហ៊ុយបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស និងផ្សេងៗ ត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាជួល ទិញសេវាកម្មបណ្តុះបណ្តាល ត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-ការថែទាំនិងជួសជុល រួមមាន ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេរ និងដែននេសាទ ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទនិងផ្សេងៗ ការថែទាំ ជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ ការថែទាំបណ្តាញផ្សេងៗ ការថែទាំប្រព័ន្ធធារាសាស្ត្រ ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស និងការថែទាំនិងជួសជុលផ្សេងៗត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាជួល ទិញសេវាកម្មជួសជុសត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-សោហ៊ុយធានារ៉ាប់រង រួមមាន សោហ៊ុយធានារ៉ាប់រងលើអគារ សោហ៊ុយធានារ៉ាប់រងលើយានយន្ត សោហ៊ុយធានារ៉ាប់រងលើសុខភាព សោហ៊ុយធានារ៉ាប់រងផ្សេងៗទៀត ត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាទិញសេវាកម្មធានារ៉ាប់រងត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-សោហ៊ុយធានារ៉ាប់រង សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា សោហ៊ុយនៃការប្រើប្រាស់សិទ្ធិត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាទិញសេវាកម្មត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

-ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ សារព័ត៌មាន និងឯកសារ សោហ៊ុយបេសកកម្មក្នុងប្រទេស សោហ៊ុយបេសកកម្មក្រៅប្រទេស ត្រូវទទួលស្គាល់នៅពេលដែលការស្នើសុំត្រូវបានទទួល និង អនុម័តដោយអាណាប័ក។

-សោហ៊ុយធនាគារ និងសំណងកិច្ចសន្យា ត្រូវទទួលស្គាល់នៅពេលកិច្ចសន្យាទិញសេវាកម្មត្រូវបានចុះហត្ថលេខា និងយោងតាមសារធាតុនៃកិច្ចសន្យា។

**៣. លក្ខខណ្ឌនៃការទទួលស្គាល់បន្ទុកហិរញ្ញវត្ថុ**

ចំណាយកើតឡើងនៅពេលដែលរាជរដ្ឋាភិបាលបានខ្ចីប្រាក់ ដែលរួមមាន ការប្រាក់ និងចំណាយនានាពាក់ព័ន្ធនឹងការខ្ចីប្រាក់របស់ស្ថាប័នសាធារណៈ។ ចំណាយទាំងនោះរួមមាន÷

-ចំណាយលើការប្រាក់ខ្ចី

-ចំណេញ ខាតពីអត្រាប្តូរប្រាក់ ពីការខ្ចីប្រាក់ជារូបិយវត្ថុបរទេស ដែលតួលេខខុសគ្នានេះត្រូវបានចាត់ចូលជាផ្នែកមួយនៃចំណាយខ្ចីប្រាក់

-បន្ទុកហិរញ្ញវត្ថុផ្សេងទៀតដែលពាក់ព័ន្ធនឹងការរៀបចំប្រាក់កម្ចី។

ស្ថាប័នសាធារណៈ ត្រូវទទួលស្គាល់ចំណាយពាក់ព័ន្ធនឹងបន្ទុកហិរញ្ញវត្ថុ នៅពេលបំពេញគ្រប់លក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷

ក.ចំណាយពីការខ្ចីប្រាក់ ត្រូវទទួលស្គាល់ជាចំណាយនៅពេលដែលការខ្ចីកើតឡើង(នៅពេលទទួលបានប្រាក់កម្ចី) និង

ខ.ការកំណត់តាមស្តង់ដា ចំណាយពីការប្រាក់កម្ចីត្រូវបានទទួលស្គាល់ជាចំណាយ ទៅតាមរយៈពេលដែលការខ្ចីកើតឡើង។

ក្នុងការអនុវត្ត ការចំណាយពាក់ព័ន្ធនឹងការរៀបចំដំណើរការ ឬ ថ្លៃស្នើសុំប្រាក់កម្ចីត្រូវបានទទួលស្គាល់ជាចំណាយទាំងស្រុងនៅពេលដែលមានការតម្រូវឱ្យបង់។ ចំពោះបន្ទុកហិរញ្ញវត្ថុ ការប្រាក់កម្ចីត្រូវទទួលស្គាល់ជាចំណាយទៅតាមរយៈពេលដែលការខ្ចីកើតឡើង។

-បន្ទុកហិរញ្ញវត្ថុពីការប្រាក់នៃបំណុលក្នុងប្រទេស រួមមាន ធនាគារជាតិនៃកម្ពុជា ធនាគារពាណិជ្ជ ប័ណ្ណរតនាគារ សញ្ញាប័ណ្ណ និងបន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត ត្រូវទទួលស្គាល់ជាចំណាយទៅតាមរយៈពេលដែលការខ្ចីកើតឡើង។ ការចំណាយពាក់ព័ន្ធនឹងការរៀបចំដំណើរការ ឬ ថ្លៃស្នើសុំប្រាក់កម្ចីត្រូវបានទទួលស្គាល់ជាចំណាយទាំងស្រុង នៅពេលដែលមានការតម្រូវឱ្យបង់ លើកលែងតែមានការកំណត់ផ្សេងពីនេះដែលបានចែងក្នុងកិច្ចព្រមព្រៀងខ្ចី។

-បន្ទុកហិរញ្ញវត្ថុពីការប្រាក់នៃបំណុលក្រៅប្រទេស រួមមាន ពហុភាគី ទ្វេភាគី ពីដៃគូអភិវឌ្ឍន៍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ត្រូវទទួលស្គាល់ជាចំណាយទៅតាមរយៈពេលដែលការខ្ចីកើតឡើង។ ការចំណាយពាក់ព័ន្ធនឹងការរៀបចំដំណើរការ ឬ ថ្លៃស្នើសុំប្រាក់កម្ចីត្រូវបានទទួលស្គាល់ជាចំណាយទាំងស្រុងនៅពេលដែលមានការតម្រូវឱ្យបង់ លើកលែងតែមានការកំណត់ផ្សេងពីនេះដែលបានចែងក្នុងកិច្ចព្រមព្រៀងខ្ចី។

### ៤. លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយមូលធន

ចំណាយកើតឡើងនៅពេលដែលរាជរដ្ឋាភិបាលបានទិញទ្រព្យសកម្មរយៈពេលវែង រួមមាន ទ្រព្យសម្បត្តិ រោងចក្រ គ្រឿងបរិក្ខារ ទ្រព្យសកម្មអរូបី និងទ្រព្យផ្សេងទៀត។ ជាទូទៅ ទ្រព្យសកម្មរយៈពេលវែង ត្រូវបានប្រើប្រាស់សម្រាប់ផលិត ឬ ផ្គត់ផ្គង់ទំនិញ ឬ សេវាកម្ម ដើម្បីជួលឱ្យអ្នកដទៃ ឬ សម្រាប់គោលបំណងរដ្ឋបាល និង ត្រូវបានប្រើប្រាស់ច្រើនជាងមួយការិយបរិច្ឆេទរាយការណ៍។

ជាកិច្ចការសំខាន់ ដែលតួលេខនៃទ្រព្យសកម្មរយៈពេលវែង រួមមាន ទ្រព្យសម្បត្តិ រោងចក្រ គ្រឿងបរិក្ខារ និងទ្រព្យផ្សេងទៀតត្រូវបានទទួលស្គាល់ និងបង្ហាញនៅក្នុងតារាងតុល្យភាព។ នៅក្នុងស្ថានភាពខ្លះ កិច្ចការសំខាន់ដែលត្រូវពិចារណា ថាតើ ទំនិញដែលទទួលបាន គួរតែត្រូវបានប្រើប្រាស់ និងទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលពេលវែង ឬ ផ្ទុយមកវិញត្រូវទទួលស្គាល់ជាចំណាយតែម្តង ដែលការទទួលស្គាល់និងកិច្ចបញ្ជិកាគណនេយ្យត្រូវអនុវត្តដូច ចំណុចទី២ **ចំណាយពីការទិញទំនិញ និងសេវាកម្ម**។ ទ្រព្យទាំងអស់នោះអាចត្រូវកត់ត្រាជាចំណាយមូលធន ដែលត្រូវទទួលស្គាល់ជាទ្រព្យទៅតាមអាយុកាលប្រើប្រាស់ ប្រសិនបើបានបំពេញលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង

ដូចខាងក្រោម÷

ក. ទ្រព្យសកម្មនោះ មានរូបរាងជារូបវ័ន្ត (លើកលែងតែទ្រព្យសកម្មរយៈពេលវែងអរូបី)

ខ. ស្ថាប័នសាធារណៈមានសិទ្ធិទទួលបានអត្ថប្រយោជន៍ ឬ ដាក់កំហិតអ្នកដទៃពីការប្រើប្រាស់ទ្រព្យសកម្មនោះ

គ. ទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ឬ សក្តានុពលសេវាកម្មដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ

ឃ. ទ្រព្យសកម្មនោះមិនត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែងសម្រាប់លក់ ហើយទ្រព្យសកម្មនោះត្រូវបានរំពឹងថានឹងប្រើប្រាស់លើសពី ១២ ខែ

ង. ថ្លៃដើមនៃទ្រព្យសកម្មនោះអាចត្រូវបានវាស់វែងជាក់លាក់ និង

ច. តម្លៃនៃទ្រព្យសកម្មនោះស្មើ ឬ លើសតម្លៃអប្បបរមានៃការទទួលស្គាល់ទ្រព្យសកម្មរយៈពេលវែង។

ជាការអនុវត្ត ការទទួលស្គាល់និងកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែងត្រូវអនុវត្តតាមការណែនាំនៃប្រកាសលេខ ៣៥៤ សហវ.ប្រក ចុះថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។

### ៥. លក្ខខណ្ឌនៃការទទួលស្គាល់ចំណាយពីការផ្ទេរ

ចំណាយពីការផ្ទេរ គឺជាការចំណាយដែលកើតចេញពីប្រតិបត្តិការមិនមែនជាបន្តុកពន្ធ ដែលអង្គភាពផ្តល់នូវទ្រព្យសកម្មជាសេវា ឬ ទ្រព្យសកម្មផ្សេងទៀត ដល់អង្គភាពមួយទៀត (ដែលអាចជាបុគ្គល) ដោយមិនទទួលបានផលជាសេវា ឬ ទ្រព្យសកម្មជាការតបស្នងដោយផ្ទាល់វិញទេ។ ឧទាហរណ៍ រាជរដ្ឋាភិបាលបានសម្រេចផ្តល់មូលនិធិជំនួយសម្រាប់គាំទ្រការអនុវត្តកម្មវិធីចំនួន៤ ០០០ ០០០រៀល ទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយមិនមានទទួលទំនិញ ឬ សេវាណាមួយដោយផ្ទាល់ជាការតបស្នងនោះទេ។ ជាទូទៅ ចំណាយពីការផ្ទេរកើតឡើងក្នុងករណី ដូចខាងក្រោម÷

ក. ចំណាយពាក់ព័ន្ធនឹងការផ្ទេរ សម្រាប់អនុវត្តកម្មវិធីរបស់អង្គភាពផ្សេងទៀតនឹងត្រូវទទួលស្គាល់ជាចំណាយផ្អែកទៅលើសេវាដែលបានផ្តល់ជូន ដោយមានមូលដ្ឋានក្នុងការរាយការណ៍។ ចំណាយបែបនេះនឹងត្រូវកត់ត្រាតាមប្រភេទនៃមាតិកាចំណាយ។

ខ. ចំណាយពាក់ព័ន្ធនឹងការផ្ទេរ ប្រភេទជាការផ្តល់ជំនួយសាច់ប្រាក់ ដែលត្រូវផ្តល់ជូនអ្នកទទួលតែម្តង។ ចំណាយនេះមិនតម្រូវឱ្យមានការកត់ត្រាតាមមុខសញ្ញាចំណាយ ឬតាមប្រភេទនៃមាតិកាចំណាយទេ។ ចំណាយត្រូវទទួលស្គាល់នៅពេលចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងការផ្តល់ជំនួយសាច់ប្រាក់។ ការសន្យាពាក់ព័ន្ធនឹងការផ្តល់ជំនួយនៅឆ្នាំបន្តបន្ទាប់ ត្រូវទទួលស្គាល់ជាបំណុលជាយថាហេតុ នឹងចុះជាចំណាយនៅដើមឆ្នាំនីមួយៗដែលមានការផ្តល់សាច់ប្រាក់។

ក្នុងការអនុវត្ត រាជរដ្ឋាភិបាលកម្ពុជាអនុវត្តចំណាយពាក់ព័ន្ធនឹងការផ្ទេរ ក្រោមរូបភាពដូចខាងក្រោម÷

-ឧបត្ថម្ភធន និងផ្តល់ជំនួយដល់អង្គភាពរាជរដ្ឋាភិបាល នៅតាមមូលដ្ឋាន អង្គការជាតិ និង អង្គការអន្តរជាតិ ស្ថាប័ន-សាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងស្ថាប័នផ្សេងទៀត។ ជាងនេះទៀត រាជរដ្ឋាភិបាលបានរួមចំណែកឧបត្ថម្ភដល់អង្គការ សមាគម និងអង្គការអន្តរជាតិនៅក្នុងតាមបណ្តាប្រទេសនានាផងដែរ។ ប្រសិនបើការឧបត្ថម្ភធន និងផ្តល់ជំនួយជាសាច់ប្រាក់ទាំងនេះ បើកផ្តល់ជូន អ្នកទទួលផលតែម្តង ចំណាយនេះមិនតម្រូវឱ្យមានការកត់ត្រាតាមប្រភេទនៃមាតិកាចំណាយទេ។ ចំណាយត្រូវទទួលស្គាល់ នៅពេលដែលមានការចុះហត្ថលេខាពីការផ្តល់ជំនួយសាច់ប្រាក់នោះ។

ការសន្យា ពាក់ព័ន្ធនឹងការផ្តល់ជំនួយឧបត្ថម្ភធននៅឆ្នាំបន្តបន្ទាប់ ត្រូវទទួលស្គាល់ជាបំណុលជាយថាហេតុ នឹងចុះជាចំណាយនៅដើមឆ្នាំនីមួយៗដែលមានការផ្តល់សាច់ប្រាក់។

-ឧបត្ថម្ភអត្ថប្រយោជន៍សង្គម រួមមាន អត្ថប្រយោជន៍របបសន្តិសុខសង្គម ជំនួយសង្គមដល់ប្រជាពលរដ្ឋ ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌។ ប្រសិនបើការឧបត្ថម្ភធន និងផ្តល់ជំនួយជាសាច់ប្រាក់ទាំងនេះ បើកផ្តល់ជូន អ្នកទទួលផលតែម្តង ចំណាយនេះមិនតម្រូវឱ្យមានការកត់ត្រាតាមប្រភេទនៃមាតិកាចំណាយទេ។ ចំណាយត្រូវទទួលស្គាល់ នៅពេលចុះហត្ថលេខាពីការផ្តល់ជំនួយសាច់ប្រាក់។ ការសន្យាពាក់ព័ន្ធនឹងការផ្តល់ជំនួយឧបត្ថម្ភធននៅឆ្នាំបន្តបន្ទាប់ ត្រូវទទួលស្គាល់ជាបំណុលជាយថាហេតុ នឹងចុះជាចំណាយនៅដើមឆ្នាំនីមួយៗដែលមានការផ្តល់សាច់ប្រាក់។

## ផ្នែកទី២

## ការវាស់វែងចំណាយ

ចំណាយចរន្តនិងចំណាយមូលធន ត្រូវបានវាស់វែងដំបូងតាមមូលដ្ឋានតម្លៃសមស្របដែលបានព្រមព្រៀងគ្នារវាងភាគីទាំងពីរដែលមានចែងនៅក្នុងកិច្ចសន្យា ឬ វិក្កយបត្រ។ ចំពោះទ្រព្យសម្បត្តិ រោងចក្រ និងគ្រឿងបរិក្ខារ ការទទួលស្គាល់ដំបូងត្រូវតែបានវាស់វែងដោយតម្លៃសមស្រប ឬ តម្លៃទីផ្សារ។ ដោយសារការកំណត់តម្លៃនៃទ្រព្យសកម្មទាំងនេះ ពាក់ព័ន្ធនឹងការកំណត់ចំណាយបង្គរផងដែរ ដូចជាការធ្វើរំលស់ និងការធ្លាក់ចុះតម្លៃរបស់ទ្រព្យសកម្ម ដែលស្ថាប័នសាធារណៈត្រូវទទួលស្គាល់ជាចំណាយរបស់អង្គភាពផងដែរ។ ការវាស់វែងបន្ទាប់នៃទ្រព្យសកម្មរយៈពេលវែង ត្រូវយកតាមតម្លៃថ្លៃដើមដករំលស់ និងការធ្លាក់ចុះតម្លៃពីការខូចខាតទ្រព្យសកម្ម(ប្រសិនបើមាន)។ ក្នុងករណីដែលមិនអាចកំណត់ថ្លៃដើមនៃទ្រព្យសកម្មបាន ការវាយតម្លៃឡើងវិញនៃទ្រព្យសកម្មនោះនឹងត្រូវបានប្រើប្រាស់ក្នុងការកំណត់តម្លៃ។

## ជំពូកទី៣

## ចំណាយបង្គរនិងបំណុលជាយថាហេតុ

ចំណាយបង្គរ ឬ គណនីត្រូវសងអាចកើតមានឡើងនៅពេលដែលស្ថាប័នសាធារណៈធ្វើប្រតិបត្តិការចំណាយ និងមិនទាន់ទូទាត់សាច់ប្រាក់ជូនអ្នកផ្គត់ផ្គង់ ដូចជា ការទទួលបានទំនិញ និង សេវាកម្ម ដោយកំពុងរង់ចាំការទូទាត់។ បំណុលជាយថាហេតុ(Contingent liability) កើតឡើងនៅពេលដែលស្ថាប័នសាធារណៈធ្វើសកម្មភាពដែលនាំឱ្យកើតបំណុលជាសក្តានុពល ដែលអាចប្រែជាបំណុលជាក់ស្តែងប្រសិនព្រឹត្តិការណ៍ពិតកើតឡើង ដូចជាការសន្យាផ្តល់ជំនួយមិនផ្លូវការ ជាដើម។

### ១. ចំណាយបង្គរ

ចំណាយបង្គរ ឬ គណនីត្រូវសងត្រូវបានទទួលស្គាល់នៅពេល ទំនិញ ឬ សេវាកម្ម ត្រូវបានទទួល ឬ ផ្គត់ផ្គង់ភ្ជាប់មកជាមួយនូវវិក្កយបត្រ ឬ ការព្រមព្រៀងគ្នាជាផ្លូវការជាមួយអ្នកលក់ ប៉ុន្តែមិនទាន់បានទូទាត់សាច់ប្រាក់នៅឡើយ( ឧទាហរណ៍ ការចំណាយលើទំនិញ និង សេវាកម្ម ដូចជា ចំណាយលើការជួល សេវាអ៊ីនធឺណិត អគ្គិសនី និងថ្លៃទឹក ជាដើម។ល។) ដែលចំណាយបង្គរនេះនឹងត្រូវទូទាត់ជាសាច់ប្រាក់នៅពេលក្រោយ។ ដូច្នេះចំណាយត្រូវទទួលស្គាល់នៅក្នុងការិយបរិច្ឆេទរាយការណ៍ដែលកើតឡើង មិនមែនទទួលស្គាល់នៅពេលសាច់ប្រាក់ទូទាត់នៅក្នុងការិយបរិច្ឆេទបន្ទាប់នោះទេ។

**ឧទាហរណ៍** ស្ថាប័នសាធារណៈ ក. បានចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការជាវអ៊ីនធឺណិតក្នុងតម្លៃ ១ លានរៀល ក្នុងមួយខែ ដោយបង់ប្រាក់ជូនអ្នកផ្តល់សេវាអ៊ីនធឺណិតរៀងរាល់៣ ខែម្តងបន្ទាប់ពីបានប្រើប្រាស់។ វិក្កយបត្រត្រូវបានផ្ញើជូនទៅស្ថាប័នសាធារណៈ ក. ក្នុងខែមករា ឆ្នាំ២០X១ សម្រាប់ថ្លៃការប្រើប្រាស់ចំនួន៣ ខែ ដោយគិតចាប់ពី ខែវិច្ឆិកា ខែធ្នូ ឆ្នាំ២០X០ និង ខែមករា ឆ្នាំ២០X១។ ដូចនេះស្ថាប័នសាធារណៈ ក. ត្រូវទទួលស្គាល់ចំណាយចំនួន២ ខែ ត្រូវនឹងទឹកប្រាក់ចំនួន២ លានរៀល ក្នុងការិយបរិច្ឆេទឆ្នាំ២០X០ ទោះបីជាការបង់ប្រាក់មិនទាន់ត្រូវបានធ្វើក៏ដោយ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. កត់ត្រាចំណាយបង្គរពីការប្រើប្រាស់អ៊ីនធឺណិតចំនួន២ខែ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី សោហ៊ុយទូរគមនាគមន៍ | ៦១១៤២ | ២ 000 000 |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤00១ | ២ 000 000 |
| **ទី២. កត់ត្រានៅពេលទូទាត់ប្រាក់ក្នុងខែមករា ឆ្នាំ២០X១** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤00១ | ២ 000 000 |
| ឥណទាន គណនី ធនាគារ | ១១.... | ២ 000 000 |

### ២. ការទទួលស្គាល់បំណុល

ការទទួលស្គាល់បំណុល(កាតព្វកិច្ចបច្ចុប្បន្ន) គឺជាកាតព្វកិច្ចចង ដែលនាំឱ្យមានការហូរចេញធនធានរបស់ស្ថាប័នសាធារណៈ។ ស្ថាប័នសាធារណៈមានជម្រើសតិចតួច ឬ គ្មានតែម្តង ដើម្បីចៀសវាងបំពេញកាតព្វកិច្ចនេះ។ ការទទួលស្គាល់បំណុល គឺជាកាតព្វកិច្ចដែលត្រូវអនុវត្តដោយជាក់លាក់ ដែលកើតឡើងមានការពាក់ព័ន្ធនឹងប្រតិបត្តិការមិនដោះដូរ។

កាតព្វកិច្ចបច្ចុប្បន្ន អាចត្រូវបានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវផ្សេងទៀត ដូចជា កាតព្វកិច្ចដាក់ប្រាក់ពិន័យ ឬ ប្រាក់ធានា។ គោលការណ៍នេះអាចកើតមានឡើងផងដែរក្នុងបរិបទនៃប្រតិបត្តិការទូទៅ ដូចជាការទទួលបានបុរេប្រទាន។

នៅក្នុងប្រតិបត្តិការប្រចាំថ្ងៃ ស្ថាប័នសាធារណៈអាចទទួលធនធានមុនពេលព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង ដូច្នេះ ចំនួនទឹកប្រាក់នៃការទទួលស្គាល់ជាបំណុល ត្រូវស្មើនឹងចំនួនទឹកប្រាក់ដែលបានទទួលមុននឹងការទទួលស្គាល់ជាព្រឹត្តិការណ៍ជាប់ពន្ធកើតឡើង។ ការទទួលស្គាល់បំណុល ដែលកើតចេញពីកាតព្វកិច្ចបច្ចុប្បន្ន អាចប្រព្រឹត្តទៅបាន លុះត្រាតែបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម÷

ក. ទំនងថាវិហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ចឬសក្តានុពលសេវាកម្មនាពេលអនាគត ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងត្រូវឱ្យមានការទូទាត់កាតព្វកិច្ច និង

ខ. ទឹកប្រាក់ដែលត្រូវទូទាត់អាចប៉ាន់ស្មានបានដោយជឿជាក់។

**ឧទាហរណ៍** នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០X៥ ក្រុមហ៊ុន ស៊ីអាយ (CI LTD) បានចូលរួមដេញថ្លៃផ្គត់ផ្គង់ក្រដាសអោយរដ្ឋ និងបានបង់ប្រាក់កក់ធានាការដេញថ្លៃ ចំនួន៨ ០០០ ០០០ ០០០រៀល ទៅក្នុងគណនីទោលរតនាគារ។ ពេលក្រុមហ៊ុន ស៊ីអាយ (CI LTD) ជោគជ័យក្នុងការដេញថ្លៃ ប្រាក់កក់នេះនឹងត្រូវប្តូរមកកក់ធានាការអនុវត្តកិច្ចសន្យាវិញ។ បន្ទាប់ពីការផ្គត់ផ្គង់ចប់សព្វគ្រប់ ក្រុមហ៊ុន ស៊ីអាយ (CI LTD) អាចដកប្រាក់នេះត្រឡប់ទៅវិញ។ ដូច្នេះ ស្ថាប័នសាធារណៈត្រូវទទួលស្គាល់សាច់ប្រាក់កក់ធានាការដេញថ្លៃ ជាបំណុល។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **កត់ត្រាបំណុលចំនួន ៨ ០០០លានរៀល នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០X៥** | | |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ៨ ០០០ ០០០ ០០០ |
| ឥណទាន គណនី ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ៤៧០៥ | ៨ ០០០ ០០០ ០០០ |

### ៣. ការទទួលស្គាល់បំណុលជាយថាហេតុ

បំណុលជាយថាហេតុ តម្រូវឱ្យមានតែការលាតត្រដាងនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ តែមិនតម្រូវឱ្យមានការទទួលស្គាល់ និងកត់ត្រាក្នុងបញ្ជីគណនេយ្យនោះទេ។ បំណុលជាយថាហេតុ ជាកាតព្វកិច្ចដែលអាចកើតឡើងពីព្រឹត្តិការណ៍កន្លងមក ហើយអាចកើតឡើងបាន អាស្រ័យទៅលើព្រឹត្តិការណ៍អនាគតមួយ ឬ ច្រើនទៀតដែលមានភាពមិនច្បាស់លាស់ និងមិនស្ថិតនៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់រាជរដ្ឋាភិបាល។ ការទទួលស្គាល់បំណុលជាយថាហេតុត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

ក. មិនទំនងថាវិហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មនាពេលអនាគត ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ នឹងត្រូវឱ្យមានការទូទាត់កាតព្វកិច្ច ឬ

ខ. មិនអាចប៉ាន់ស្មានលើទឹកប្រាក់ដែលត្រូវទូទាត់កាតព្វកិច្ច ដោយជឿជាក់បាន។

រាជរដ្ឋាភិបាលត្រូវបង្ហាញអំពីបំណុលជាយថាហេតុនេះ ទៅតាមកម្រិតហានិភ័យក្នុងការរាយការណ៍នៅការិយបរិច្ឆេទរាយការណ៍ ដោយមានព័ត៌មានអំពីលក្ខណៈនៃបំណុលជាយថាហេតុនេះ លើកលែងតែលទ្ធភាពនៃការហូរចេញធនធាន

សម្រាប់ទូទាត់ត្រូវបានលុបចោល។

នៅក្នុងការអនុវត្តជាក់ស្តែង ក្នុងករណីរាជរដ្ឋាភិបាលមានការសន្យាដោយផ្ទាល់មាត់ ចំពោះការផ្តល់ជំនួយមានលក្ខណៈជាច្រើនឆ្នាំ ដល់អង្គភាពផ្សេងទៀត និង/ឬ ស្ថិតនៅក្រោមនីតិវិធីតតាំងផ្លូវច្បាប់ស្វែងរកសំណងការខូចខាត (កាតព្វកិច្ចបច្ចុប្បន្ន) ពីផលប៉ះពាល់ទ្រព្យសម្បត្តិរបស់ខ្លួន ព្រឹត្តិការណ៍ទាំងនេះត្រូវបានចាត់ទុកជាបំណុលជាយថាហេតុ។ **ឧទាហរណ៍** ក្នុងការប្តឹងផ្តល់ផ្លូវច្បាប់ទាមទារសំណង ប្រសិនបើមានការប្តឹងជំទាស់ពីស្ថាប័នសាធារណៈទៅលើបណ្តឹងនោះ ដោយមានការផ្តល់យោបល់ពីមេធាវីពីលទ្ធភាពដែលស្ថាប័នសាធារណៈត្រូវមានកាតព្វកិច្ចសងសំណងនោះ គឺគ្មាន។ ក្នុងករណីនេះ គ្មានសំណងណាមួយត្រូវបានទទួលស្គាល់ជាចំណាយនោះទេ គ្រាន់តែ ត្រូវដាក់បង្ហាញជាបំណុលជាយថាហេតុ រហូតទាល់តែលទ្ធភាពនៃការទូទាត់ត្រូវបានចាត់ទុកថាលែងមាន។

**៤. ចំណាយពន្យារ**

ចំណាយពន្យារ ឬ ការបង់ប្រាក់ទូទាត់ជាមុនមិនត្រូវបានរាយការណ៍ក្នុងរបាយការណ៍ចំណូល ចំណាយទេ។ ផ្ទុយទៅវិញចំណាយពន្យារ ត្រូវបានកត់ត្រាថាជាទ្រព្យសកម្ម នៅក្នុងតារាងតុល្យការ រហូតដល់ចំណាយត្រូវបានទទួលស្គាល់។ នៅពេលចំណាយបានកើតឡើង នាំឱ្យទ្រព្យសកម្មត្រូវថយចុះ ហើយការចំណាយនោះនឹងត្រូវបានកត់ត្រា នៅលើរបាយការណ៍ចំណូល ចំណាយ។ ចំណាយពន្យារមានដូចជា ការបង់ប្រាក់មុនទៅតាមការកំណត់របស់អ្នកផ្គត់ផ្គង់ទៅលើការប្រើប្រាស់សេវាកម្ម ការជួល ជាដើម។

**ឧទាហរណ៍÷ ការជួលអគារ**

ក្រសួង ក. បានចុះកិច្ចសន្យាជួលអគារទំនេរនិងមិនប្រើប្រាស់ពីក្រុមហ៊ុនភ្នំពេញថ្មីរ ក្នុងតម្លៃ៦ ០០០ ០០០រៀល ក្នុងមួយខែ។ កិច្ចសន្យាតម្រូវឱ្យភាគីអ្នកជួលបង់ថ្លៃឈ្នួលប្រចាំខែជាមុនក្នុងរយៈពេលយ៉ាងយូរត្រឹមថ្ងៃទី១០ បន្ទាប់ពីទទួលបានវិក្កយបត្រទូទាត់។ វិក្កយបត្រទទួលបាននៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០X១ សម្រាប់ថ្លៃជួលក្នុងខែមេសា។

**កិច្ចបញ្ជិកាគណនេយ្យ**

| | **មាតិកាគណនី** | **ចំនួនជារៀល** |
|---|---|---|
| **ទី១. ពេលទទួលបានវិក្កយបត្រ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០X១** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ ឥណាយិក | ១៥០៥៥ | ៦ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ៦ ០០០ ០០០ |
| **ទី២. កាត់ចូលជាចំណាយក្នុងខែមេសា ឆ្នាំ២០X១** | | |
| ឥណពន្ធ គណនី ថ្លៃឈ្នួល និងបន្ទុក (អសង្ហារឹម) ក្នុងប្រទេស | ៦១០៣១ | ៦ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ ឥណាយិក | ១៥០៥៥ | ៦ ០០០ ០០០ |

## ជំពូកទី៤

## គណនេយ្យកម្មលើការទទួលស្គាល់ចំណាយ

ស្ថាប័នសាធារណៈត្រូវទទួលស្គាល់ចំណាយ និងចំណាយបង្គរ នៅពេលដែលព្រឹត្តិការណ៍ដែលនាំឱ្យចំណាយនោះកើតឡើង។ ចំពោះព្រឹត្តិការណ៍ដែលនាំឱ្យមានចំណាយ និងចំណាយបង្គរសម្រាប់ស្ថាប័នសាធារណៈមានដូចខាងក្រោម÷

**ក. ចំណាយបន្ទុកបុគ្គលិក** កើតឡើងនៅពេលដែលស្ថាប័នសាធារណៈបានប្រើប្រាស់សេវាកម្មការងារ ដែលធ្វើឡើងដោយមន្ត្រីបុគ្គលិករបស់ខ្លួន ក្នុងនោះ ចំណាយបន្ទុកបុគ្គលិក រួមមាន ប្រាក់បៀវត្ស អត្ថប្រយោជន៍រយៈពេលខ្លី អត្ថប្រយោជន៍រយៈពេលវែង និង អត្ថប្រយោជន៍ផ្សេងទៀតរបស់បុគ្គលិក។

**ខ. ចំណាយពីការទិញទំនិញ និងសេវាកម្ម** ចំណាយកើតឡើងនៅពេលដែលស្ថាប័នសាធារណៈបានទិញទំនិញ និងសេវាកម្មពីអ្នកផ្គត់ផ្គង់។ ចំណាយត្រូវទទួលស្គាល់ នៅពេលដែលទិញទំនិញ ឬ សេវាកម្មត្រូវបានប្រគល់ និងទទួល។

**គ. បន្ទុកហិរញ្ញវត្ថុ** ចំណាយកើតឡើងនៅពេលដែលស្ថាប័នសាធារណៈបានខ្ចីប្រាក់ ដែលរួមមាន ការប្រាក់ និង ចំណាយនានាពាក់ព័ន្ធនឹងការខ្ចីប្រាក់របស់ស្ថាប័នសាធារណៈដោយគិតតាមរយៈពេលនៃការខ្ចី។

**ឃ. ចំណាយមូលធន** ចំណាយកើតឡើងនៅពេលដែលស្ថាប័នសាធារណៈបានទិញទ្រព្យសកម្មរយៈពេលវែង រួមមាន ទ្រព្យសម្បត្តិ រោងចក្រ គ្រឿងបរិក្ខារ ទ្រព្យសកម្មអរូបី និងទ្រព្យផ្សេងទៀត។ ប្រសិនបានបំពេញលក្ខខណ្ឌនៃការទទួលស្គាល់ជាទ្រព្យសកម្មៈពេលវែង ចំណាយមូលធននេះត្រូវទទួលស្គាល់ជាចំណាយតាមអាយុកាលប្រើប្រាស់ ឬ ផ្ទុយមកវិញចំណាយមូលធននេះត្រូវទទួលស្គាល់ជាចំណាយចរន្តទាំងអស់តែម្តង។

**ង. ចំណាយពីការផ្ទេរ** ចំណាយកើតឡើងនៅពេលដែលស្ថាប័នសាធារណៈ ផ្តល់ធនធានជាសេវា ឬ ទ្រព្យសកម្មផ្សេងទៀតដល់អង្គភាពមួយទៀត (ដែលអាចជានិតិបុគ្គល) ដោយមិនទទួលបានផលជាសេវា ឬ ទ្រព្យសកម្មជាការតបស្នងដោយផ្ទាល់វិញទេ។

**ច. សំណេសចំណាយ** គឺជាការទទួលបានមកវិញនូវសាច់ប្រាក់ ដែលត្រូវបានចាត់ជាចំណាយរបស់ស្ថាប័នសាធារណៈរួចហើយ ដែលសំដៅលើចំណាយដែលពាក់ព័ន្ធនឹងប្រាក់បៀវត្ស និងប្រាក់បង្វិលសងពីស្ថាប័នសាធារណៈនានារបស់រាជរដ្ឋាភិបាល។ តាមស្តង់ដាគណនេយ្យសាធារណៈលេខ ១ អំពីការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុនៃគណនេយ្យមូលដ្ឋានបង្គរត្រូវធ្វើឡើងតាមគោលការណ៍និរន្តភាព(ongoing concern basis)។ ដូចនេះ ការធ្វើកិច្ចបញ្ជិកាគណនេយ្យនៃសំណេសចំណាយ ត្រូវអនុវត្តដូចខាងក្រោម÷

-បើសំណេសចំណាយនោះកើតក្នុងឆ្នាំ កិច្ចបញ្ជិកាគណនេយ្យត្រូវកាត់កងនឹងចំណាយក្នុងឆ្នាំ

-បើសំណេសចំណាយនោះកើតឆ្លងឆ្នាំ កិច្ចបញ្ជិកាគណនេយ្យត្រូវចាត់ជាចំណូលក្នុងឆ្នាំបន្ទាប់។

**ឆ. ការបង្វិលសងនៃពន្ធលើតម្លៃបន្ថែម** គឺជាការបង្វិលសងអាករលើតម្លៃបន្ថែមជាសាច់ប្រាក់ជូនអ្នកបង់ពន្ធវិញតាមការស្នើសុំ ក្នុងករណីដែលបុគ្គល ឬអ្នកជាប់ពន្ធមធ្យម និងពន្ធធំ ឬស្ថានកុងស៊ុលបរទេស ឬភ្នាក់ងារកិច្ចសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលបរទេសនានាពុំអាចទទួលបានការបង្វិលសងអាករលើតម្លៃបន្ថែមនេះ តាមរយៈការផ្គត់ផ្គង់ទំនិញ ឬ សេវាកម្មទៅអតិថិជននៅលើទីផ្សារ។ ដូចនេះ ការធ្វើកិច្ចបញ្ជិកាគណនេយ្យ ការបង្វិលសងអាករលើតម្លៃបន្ថែម

ត្រូវអនុវត្តស្របតាមគោលការណ៍នៃស្តង់ដាស្តីពីចំណូល។

ដើម្បីផ្តល់ភាពងាយស្រួលក្នុងការអនុវត្តនិងផ្សារភ្ជាប់ជាមួយលក្ខខណ្ឌក្នុងការទទួលស្គាល់ មុខសញ្ញាចំណាយនីមួយៗរបស់ស្ថាប័នសាធារណៈ ឧទាហរណ៍ខាងក្រោម ត្រូវបានរៀបចំតាមប្រភេទ និងតាមមាតិកាចំណាយរួមមាន÷

**១. ចំណាយបន្ទុកបុគ្គលិក**

**ឧទាហរណ៍ទី១÷ ចំណាយប្រាក់ខែរបស់មន្ត្រីរាជការសាធារណៈ**

ប្រាក់ខែសម្រាប់មន្ត្រីរាជការសាធារណៈ នៅក្នុងក្របខ័ណ្ឌអចិន្ត្រៃយ៍ត្រូវបើកផ្តល់ ២ ដង ក្នុងមួយខែ លើកទី១ ចំនួន ៥០% ក្នុងសប្តាហ៍ទី ២ និងលើកទី២ ចំនួន ៥០% ផ្សេងទៀតក្នុងសប្តាហ៍ទី ៤ ក្នុងខែ តាមរយៈការផ្ទេរចូលគណនីធនាគារ។ ក្រសួងមុខងារសាធារណៈបានរៀបចំប្រាក់បៀវត្សប្រចាំខែចូល FMIS សម្រាប់ខែកក្កដា ឆ្នាំ២០X២ ចំនួន២០០ ០០០ ០០០រៀល នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០X២។

**កិច្ចបញ្ជិកាគណនេយ្យ**

| | **មាតិកាគណនី** | **ចំនួនជារៀល** |
|---|---|---|
| **នៅពេលទទួលបានតួលេខប្រាក់បៀវត្សប្រចាំខែកក្កដា នាថ្ងៃទី១០** | | |
| ឥណពន្ធ គណនី បៀវត្សមូលដ្ឋាន | ៦៤០២១ | ២០០ ០០០ ០០០ |
| ឥណទាន គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង | ៤២០១ | ២០០ ០០០ ០០០ |
| **នៅពេលបើកផ្តល់ទី១ ៥០% ខែកក្កដា ឆ្នាំ២០X២** | | |
| ឥណពន្ធ គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង | ៤២០១ | ១០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ១០០ ០០០ ០០០ |
| **នៅពេលបើកផ្តល់ទី២ ៥០% ខែកក្កដា ឆ្នាំ២០X២** | | |
| ឥណពន្ធ គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង | ៤២០១ | ១០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ១០០ ០០០ ០០០ |

**ឧទាហរណ៍ទី២÷ ចំណាយលើការបង្រៀនថែមម៉ោង**

ចំណាយលើការបង្រៀនថែមម៉ោងសម្រាប់គ្រូដែលផ្តល់ការបណ្តុះបណ្តាលពិសេស ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និង កីឡា នៅខែកញ្ញា ឆ្នាំ២០X០។ ក្រសួងបានដាក់សំណើសុំប្រាក់ចំនួន៤ ០០០ ០០០រៀល ដើម្បីទូទាត់ផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមពីលើប្រាក់បៀវត្ស ប្រចាំខែដល់គ្រូដែលបានបង្រៀនថែមម៉ោង។

**កិច្ចបញ្ជិកាគណនេយ្យ**

| | **មាតិកាគណនី** | **ចំនួនជារៀល** |
|---|---|---|
| **ពេលទទួលបានសំណើទូទាត់** | | |
| ឥណពន្ធ គណនី ប្រាក់បំណាច់ម៉ោងបន្ថែម | ៦៤០២៣ | ៤ ០០០ ០០០ |
| ឥណទាន គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង | ៤២០១ | ៤ ០០០ ០០០ |
| **នៅពេលទូទាត់** | | |

| | | |
|---|---|---|
| ឥណពន្ធ គណនី ប្រាក់បៀវត្សនិងលាភការត្រូវសង | ៤២០១ | ៤ 000 000 |
| ឥណទាន គណនី ធនាគារ | ១១.... | ៤ 000 000 |

**២. ចំណាយពីការទិញទំនិញ និងសេវាកម្ម**

**ឧទាហរណ៍ទី១÷ ការទិញទំនិញ**

នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០X៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទិញស្រូវចំនួន ១០តោន ពីពាណិជ្ជករ និងបានទទួលស្រូវពីពាណិជ្ជករដែលមានតម្លៃជាទឹកប្រាក់ចំនួន១០០ 000 000រៀល។ ក្រសួងបានទទួលវិក្កយបត្រ ប័ណ្ណដឹកទំនិញ និងស្រូវ ព្រមទាំងបានចុះហត្ថលេខាទទួលស្រូវនៅថ្ងៃតែមួយ។

នៅពេលដែលទទួលបានទំនិញ វិក្កយបត្រ និងប័ណ្ណដឹកទំនិញ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអាចទទួលស្គាល់ចំណាយ ដោយសារតែក្រសួងបានដឹងពីទឹកប្រាក់ចំណាយ ហានិភ័យ និងសិទ្ធិក្នុងនាមជាម្ចាស់ទំនិញត្រូវបានផ្ទេរទៅក្រសួង ហើយពាណិជ្ជករក៏បានបំពេញកាតព្វកិច្ចរួចរាល់។ នៅពេលទំនិញត្រូវបានប្រគល់ជូន ក្រសួងអាចទទួលស្គាល់ជាចំណាយបាន ហើយត្រូវកត់ត្រាក្នុងគណនីត្រូវសងនូវចំនួនទឹកប្រាក់ដែលនឹងទូទាត់ជូនពាណិជ្ជករ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. នៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០X៣ ពេលទទួលបានវិក្កយបត្រនិងស្រូវ** | | |
| ឥណពន្ធ គណនី ស្បៀង | ៦០០៣១ | ១០០ 000 000 |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ១០០ 000 000 |

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០X៣ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានទូទាត់សាច់ប្រាក់១០០ 000 000រៀលជូនពាណិជ្ជករសម្រាប់ការទិញស្រូវដែលបានដឹកជញ្ជូនរួចរាល់។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី២. ពេលទូទាត់នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០X៣** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ១០០ 000 000 |
| ឥណទាន គណនី ធនាគារ | ១១.... | ១០០ 000 000 |

**ឧទាហរណ៍ទី២÷ ការជាវសេវាអ៊ីនធឺណិត**

ស្ថាប័នសាធារណៈ ក បានចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការជាវអ៊ីនធឺណិតក្នុងតម្លៃ១ លានរៀល ក្នុងមួយខែ ដោយបង់ប្រាក់ជូនអ្នកផ្តល់សេវាអ៊ីនធឺណិតរៀងរាល់ ៣ ខែម្តងបន្ទាប់ពីបានប្រើប្រាស់។ ដូច្នេះ វិក្កយបត្រត្រូវបានផ្ញើជូនទៅស្ថាប័នសាធារណៈ ក ក្នុងខែមករា ឆ្នាំ២០X១ សម្រាប់ថ្លៃការប្រើប្រាស់ចំនួន៣ ខែ ដោយគិតចាប់ពី ខែវិច្ឆិកា ខែធ្នូ ឆ្នាំ២០X០ និង ខែមករា ឆ្នាំ២០X១។ ដូចនេះស្ថាប័នសាធារណៈ ក ត្រូវទទួលស្គាល់ការចំណាយចំនួន២ ខែ ចំនួន២លានរៀល ក្នុងការិយបរិច្ឆេទឆ្នាំ២០X០ ដោយផ្អែកលើកិច្ចសន្យា ទោះបីជាការបង់ប្រាក់មិនទាន់ត្រូវបានធ្វើក៏ដោយ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **១. កត់ត្រាចំណាយបង្គរពីការប្រើប្រាស់អ៊ីនធឺណិតចំនួន២ខែ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី សោហ៊ុយទូរគមនាគមន៍ | ៦១១៤២ | ២ 000 000 |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ២ 000 000 |
| **២. កត់ត្រានៅពេលទូទាត់ប្រាក់ក្នុងខែមករា ឆ្នាំ២០X១** | | |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ២ 000 000 |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ២ 000 000 |

**៣. បន្ទុកហិរញ្ញវត្ថុ**

**ឧទាហរណ៍ទី១÷ បន្ទុកហិរញ្ញវត្ថុលើការប្រាក់កម្ចី**

នៅថ្ងៃទី១ ខែមករា ឆ្នាំ២០X០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានព្រមព្រៀងទទួលប្រាក់កម្ចីចំនួន ៥ 000 000ដុល្លារ ក្រោមប្រាក់កម្ចីទ្វេភាគីពីសាធារណរដ្ឋកូរ៉េ ដែលមានឥណប្រតិទាន ៥ ឆ្នាំ ក្នុងអត្រាការប្រាក់ ៥% ក្នុង១ឆ្នាំ ជាមួយនឹងលក្ខខណ្ឌពិសេសក្នុងការសងត្រលប់ប្រាក់ដើមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៤ ប៉ុន្តែត្រូវបង់ការប្រាក់រៀងរាល់ឆ្នាំ។ តារាងកាលវិភាគទូទាត់លម្អិតត្រូវបានកំណត់ដូចខាងក្រោម÷

| កាលបរិច្ឆេទ | ប្រាក់ដើមជាដុល្លារ | ការប្រាក់ជាដុល្លារ | សមតុល្យប្រាក់ដើមដែលនៅសល់ | ការទូទាត់ដោយក្រសួង |
|---|---|---|---|---|
| ថ្ងៃទី១ ខែមករា ឆ្នាំ២០X០ | ៥ 000 000 | 0 | ៥ 000 000 | 0 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០ | ៥ 000 000 | ២៥0 000 | ៥ 000 000 | ២៥0 000 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X១ | ៥ 000 000 | ២៥0 000 | ៥ 000 000 | ២៥0 000 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X២ | ៥ 000 000 | ២៥0 000 | ៥ 000 000 | ២៥0 000 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៣ | ៥ 000 000 | ២៥0 000 | ៥ 000 000 | ២៥0 000 |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៤ | ៥ 000 000 | ២៥0 000 | 0 | ៥ ២៥0 000 |
| | **សរុប** | **១ ២៥0 000** | **0** | **៦ ២៥0 000** |

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជាដុល្លារ |
|---|---|---|
| **ទី១. កត់ត្រាការទទួលប្រាក់កម្ចីនៅថ្ងៃទី១ ខែមករា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ៥ 000 000 |
| ឥណទាន គណនី ការខ្ចីក្រៅប្រទេស ទ្វេភាគី | ៥០០២២ | ៥ 000 000 |
| **ទី២. ការបង្គរចំណាយការប្រាក់ប្រចាំខែ** | | |
| ឥណពន្ធ គណនី ទ្វេភាគី | ៦៦០២២ | ២០ ៨៣៣,៣៣ |

| | | |
|---|---|---|
| ឥណទាន គណនី ប្រាក់ដើម ការប្រាក់ និងវិភាគទានត្រូវសង | ៤០០២ | ២០ ៨៣៣,៣៣ |
| **ចំណាយការប្រាក់សរុបប្រចាំឆ្នាំ(២០ ៨៣៣,៣៣ x ១២) ២៥០ ០០០ដុល្លារ** | | |
| **ទី៣. ពេលទូទាត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ប្រាក់ដើម ការប្រាក់ និងវិភាគទានត្រូវសង | ៤០០២ | ២៥០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ២៥០ ០០០ |

**ឧទាហរណ៍ទី២÷ បន្ទុកហិរញ្ញវត្ថុពីការខ្ចីប្រាក់ពីធនាគារ ADB**

នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X០ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានយល់ព្រមទទួលប្រាក់កម្ចីចំនួន ៥ ០០០ ០០០ដុល្លារ ក្រោមប្រាក់កម្ចីពហុភាគីពីធនាគារ ADB ដែលមានឥណប្រតិទាន ៥ ឆ្នាំ ក្នុងអត្រាការប្រាក់ ៥% ក្នុង ១ឆ្នាំ ជាមួយនឹងលក្ខខណ្ឌពិសេសក្នុងការសងត្រលប់ប្រាក់ដើមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៤ ប៉ុន្តែត្រូវបង់ការប្រាក់រៀងរាល់ឆ្នាំ។ តារាងកាលវិភាគទូទាត់លម្អិត ត្រូវបានកំណត់ដូចខាងក្រោម÷

| កាលបរិច្ឆេទ | ប្រាក់ដើមជាដុល្លារ | ការប្រាក់ជាដុល្លារ | សមតុល្យប្រាក់ដើមដែលនៅសល់ | ការទូទាត់ដោយក្រសួង |
|---|---|---|---|---|
| ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X០ | ៥ ០០០ ០០០ | ០ | ៥ ០០០ ០០០ | ០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០ | ៥ ០០០ ០០០ | ១២៥ ០០០ | ៥ ០០០ ០០០ | ១២៥ ០០០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X១ | ៥ ០០០ ០០០ | ២៥០ ០០០ | ៥ ០០០ ០០០ | ២៥០ ០០០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X២ | ៥ ០០០ ០០០ | ២៥០ ០០០ | ៥ ០០០ ០០០ | ២៥០ ០០០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៣ | ៥ ០០០ ០០០ | ២៥០ ០០០ | ៥ ០០០ ០០០ | ២៥០ ០០០ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X៤ | ៥ ០០០ ០០០ | ២៥០ ០០០ | ០ | ៥ ២៥០ ០០០ |
| | **សរុប** | **១ ១២៥ ០០០** | **០** | **៦ ១២៥ ០០០** |

**កិច្ចបញ្ជិកាគណនេយ្យ**

| | **មាតិកាគណនី** | **ចំនួនជាដុល្លារ** |
|---|---|---|
| **ទី១. កត់ត្រាការទទួលប្រាក់កម្ចីនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ៥ ០០០ ០០០ |
| ឥណទាន គណនី ការខ្ចីក្រៅប្រទេស ពហុភាគី | ៥០០២១ | ៥ ០០០ ០០០ |
| **ទី២. ការបង្គរចំណាយការប្រាក់ប្រចាំខែ** | | |
| ឥណពន្ធ គណនី ពហុភាគី | ៦៦០២១ | ២០ ៨៣៣,៣៣ |
| ឥណទាន គណនី ប្រាក់ដើម ការប្រាក់ និងវិភាគទានត្រូវសង | ៤០០២ | ២០ ៨៣៣,៣៣ |
| **ចំណាយការប្រាក់សរុបប្រចាំឆ្នាំ(២០ ៨៣៣,៣៣ x ៦) ១២៥ ០០០ដុល្លារ** | | |
| **ទី៣. ពេលទូទាត់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០X០** | | |

| | | |
|---|---|---|
| ឥណពន្ធ គណនី ប្រាក់ដើម ការប្រាក់ និងវិភាគទានត្រូវសង | ៤០០២ | ១២៥ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ១២៥ ០០០ |

**៤. ចំណាយមូលធន**

**ឧទាហរណ៍ទី១÷ ចំណាយរំលស់ផ្លូវ**

ក្រសួងសាធារណការនិងដឹកជញ្ជូនសាងសង់ផ្លូវលេខ៥៥ ដោយចំណាយអស់ទឹកប្រាក់សរុបចំនួន៤ ៥០០ ០០០ ០០០រៀល។ ផ្លូវលេខ៥៥នេះ ត្រូវបានស្ថាបនារួចរាល់ជាស្ថាពរ និងត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មរយៈពេលវែងដោយគណនេយ្យករសាធារណៈនៅថ្ងៃទី២ ខែមករា ឆ្នាំ២០x១។ អាយុកាលប្រើប្រាស់ផ្លូវមានរយៈពេល៣០ឆ្នាំ និងមានតម្លៃកាកសំណល់ស្មើសូន្យ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរសម្រាប់ការគណនាចំណាយរំលស់។

$$\text{ចំណាយរំលស់ផ្លូវក្នុងមួយឆ្នាំ} = \frac{៤\ ៥០០\ ០០០\ ០០០ - 0}{៣០} = ១៥០\ ០០០\ ០០០\text{រៀល}$$

**កិច្ចបញ្ជិកាគណនេយ្យ**

| | **មាតិកាគណនី** | **ចំនួនជារៀល** |
|---|---|---|
| **ទី១. កិច្ចបញ្ជិកាចំណាយមូលធន (ទទួលស្គាល់ទ្រព្យសកម្ម)** | | |
| ឥណពន្ធ គណនី ផ្លូវថ្នល់ ផ្លូវទឹក | ២១០៤១ | ៤ ៥០០ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤ ៥០០ ០០០ ០០០ |
| **ទី២. ពេលទូទាត់** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤ ៥០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.. | ៤ ៥០០ ០០០ ០០០ |
| **ទី៣. ចំណាយរំលស់ផ្លូវ ក្នុងឆ្នាំ២០X១** | | |
| ឥណពន្ធ គណនី ទាយជ្ជទានឱ្យរំលស់អចលនកម្មរូបី | ៦៨០១២ | ១៥០ ០០០ ០០០ |
| ឥណទាន គណនី រំលស់ផ្លូវថ្នល់ | ២៨០៤១ | ១៥០ ០០០ ០០០ |

**ឧទាហរណ៍ទី២÷ រំលស់រថយន្ត**

ក្រសួង ក. ទិញរថយន្ត១គ្រឿងអស់ទឹកប្រាក់ចំនួន២៦០ ០០០ ០០០រៀល នៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០x១។ រថយន្តមានអាយុកាលប្រើប្រាស់ ៥ឆ្នាំ និងមានតម្លៃកាកសំណល់ចំនួន២០ ០០០ ០០០រៀល ព្រមទាំងប្រើប្រាស់វិធីសាស្ត្ររំលស់ថេរសម្រាប់ការគណនាចំណាយរំលស់។

$$\text{រំលស់រថយន្តក្នុងមួយឆ្នាំ} = \frac{២៦០\ ០០០\ ០០០ - ២០\ ០០០\ ០០០}{៥} = ៤៨\ ០០០\ ០០០\text{រៀល}$$

$$\text{រំលស់រថយន្តក្នុងមួយខែ} = \frac{៤៨\ ០០០\ ០០០}{១២} = ៤\ ០០០\ ០០០\text{រៀល}$$

រំលស់រថយន្តសម្រាប់ការិយបរិច្ឆេទរាយការណ៍ = ៤ ០០០ ០០០រៀល x ៧ ខែ = ២៨ ០០០ ០០០រៀល

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. កិច្ចបញ្ជិកាចំណាយមូលធន (ទទួលស្គាល់ទ្រព្យសកម្ម)** | | |
| ឥណពន្ធ គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន | ២១០៨១ | ២៦០ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ២៦០ ០០០ ០០០ |
| **ទី២. ពេលទូទាត់** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ២៦០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.. | ២៦០ ០០០ ០០០ |
| **ទី៣. ចំណាយរំលស់រថយន្ត ក្នុងឆ្នាំ២០X១** | | |
| ឥណពន្ធ គណនី ទាយជ្ជទានឱ្យរំលស់អចលនកម្មរូបី | ៦៨០១២ | ២៨ ០០០ ០០០ |
| ឥណទាន គណនី សម្ភារ ឧបករណ៍ដឹកជញ្ជូន | ២៨០៨១ | ២៨ ០០០ ០០០ |

**៥. ចំណាយពីការផ្ទេរ**

**ឧទាហរណ៍ទី១÷ អំណោយជាមូលនិធិ**

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០X០ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើការផ្តល់ជំនួយហិរញ្ញវត្ថុដល់មូលនិធិក្នុងស្រុកសម្រាប់គាំពារសង្គមដល់ប្រជាជនដែលរងផលប៉ះពាល់ភាគច្រើននៃគ្រោះមហន្តរាយធម្មជាតិ មានទឹកប្រាក់ចំនួន៥០០ ០០០ ០០០រៀល ដែលនឹងត្រូវបើកផ្តល់នៅក្នុងខែមិថុនា ឆ្នាំ២០X០។ ចំណាយពីការផ្ទេរនេះចាត់ទុកថាជាការផ្តល់ជំនួយទាំងស្រុង ដោយសាច់ប្រាក់ទាំងអស់ ត្រូវបើកផ្តល់ជូនអ្នកទទួល។ ប្រតិបត្តិការនេះនឹងត្រូវទទួលស្គាល់ជាចំណាយ នៅពេលមានការចុះហត្ថលេខាផ្តល់ជូនជាផ្លូវការក្នុងឆ្នាំ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. កត់ត្រាចំណាយ នៅខែឧសភា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ជំនួយដល់ប្រជាជនសម្រាកពេទ្យ និងចំណាយដំណើរការ របស់មណ្ឌលថែទាំសុខភាព | ៦២០២១ | ៥០០ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៥០០ ០០០ ០០០ |
| **ទី២. កត់ត្រាពេលសាច់ប្រាក់ត្រូវបានបើកផ្តល់ ក្នុងឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៥០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ៥០០ ០០០ ០០០ |

***ឧទាហរណ៍ទី២÷ អំណោយជាឧបត្ថម្ភធន***

នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០X០ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើការឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈ

រដ្ឋបាលមានទឹកប្រាក់ចំនួន៥០០ ០០០ ០០០រៀល ដែលនឹងត្រូវបើកផ្តល់នៅក្នុងខែមិថុនា ឆ្នាំ២០X០។ ចំណាយពីការផ្ទេរនេះចាត់ទុកថាជាការផ្តល់ជំនួយទាំងស្រុង ដោយសាច់ប្រាក់ទាំងអស់ ត្រូវបើកផ្តល់ជូនអ្នកទទួលទាំងស្រុង។ ប្រតិបត្តិការនេះនឹងត្រូវទទួលស្គាល់ជាចំណាយ នៅពេលចុះហត្ថលេខាផ្តល់ជូនជាផ្លូវការក្នុងឆ្នាំ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. កត់ត្រាចំណាយ នៅខែឧសភា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ឧបត្ថម្ភធនជាហិរញ្ញវត្ថុដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | ៦៥០៣១ | ៥០០ ០០០ ០០០ |
| ឥណទាន គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលជាប្រាក់រៀល | ៤៤០៥១ | ៥០០ ០០០ ០០០ |
| **ទី២. កត់ត្រាពេលសាច់ប្រាក់ត្រូវបានបើកផ្តល់ ក្នុងឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាប្រាក់រៀល | ៤៤០៥១ | ៥០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ៥០០ ០០០ ០០០ |

**៦. សំណោសចំណាយ**

**ឧទាហរណ៍ទី១÷ សំណោសចំណាយក្នុងឆ្នាំ**

ប្រាក់ខែសម្រាប់មន្ត្រីសាធារណៈសម្រាប់ខែឧសភា ឆ្នាំ២០X០ ចំនួន២ ៥០០ ០០០ ០០០រៀល ត្រូវបានបើកផ្តល់រួចរាល់ក្នុងសប្តាហ៍ទី បួន នៃខែឧសភា ឆ្នាំ២០X០។ ទោះជាយ៉ាងណាក៏ដោយ ក្រសួង ក. មួយចំនួនបានបង្វិលប្រាក់ខែសងមកវិញដោយសារតែមន្ត្រីមួយចំនួនបានស្លាប់ ឬ លាលែងពីតំណែងតែនៅទទួលបានប្រាក់ខែ។ ទឹកប្រាក់បង្វិលសងវិញមានចំនួន២០ ០០០ ០០០រៀល ក្នុងខែមិថុនា ឆ្នាំ២០X០។ ក្នុងករណីនេះសំណោសចំណាយប្រាក់ខែបានកើតឡើងដែលត្រូវកាត់ចេញពីខ្ទង់ចំណាយប្រាក់ខែ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. កត់ត្រាចំណាយប្រាក់ខែ នៅថ្ងៃ៣០ ខែឧសភា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី បៀវត្សមូលដ្ឋាន | ៦៤០២១ | ២ ៥០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ២ ៥០០ ០០០ ០០០ |
| **ទី២. កត់ត្រាពេលមានសំណោសចំណាយក្នុងខែមិថុនា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ២០ ០០០ ០០០ |

| | | |
|---|---|---|
| ឥណទាន គណនី បៀវត្សមូលដ្ឋាន | ៦៤០២១ | ២០ ០០០ ០០០ |

**បញ្ជាក់៖លេខនាគណនេយ្យខាងលើនេះ ពុំបានបង្ហាញគណនីចម្លងបណ្តោះអាសន្នទេ។**

**ឧទាហរណ៍ទី២៖ សំណោសចំណាយឆ្លងឆ្នាំ**

ប្រាក់ខែមន្ត្រីសាធារណៈសម្រាប់ខែឧសភា ឆ្នាំ២០X០ ចំនួន២ ៥០០ ០០០ ០០០រៀល ត្រូវបានបើកផ្តល់រួចរាល់ក្នុងសប្តាហ៍ទីបួននៃខែឧសភា ឆ្នាំ២០X០។ ទោះជាយ៉ាងណាក៏ដោយ ក្រសួង ក. បានបង្វិលប្រាក់ខែសងមកវិញដោយសារតែមន្ត្រីមួយចំនួនបានស្លាប់ ឬ លាលែងពីតំណែង ប៉ុន្តែនៅមិនទាន់កាត់ចេញពីតារាងបៀវត្ស។ ទឹកប្រាក់បង្វិលសងវិញមានចំនួន២០ ០០០ ០០០រៀល ក្នុងខែមករា ឆ្នាំ២០X១។ ក្នុងករណីនេះ សំណោសចំណាយប្រាក់ខែបានកើតឡើង ដែលត្រូវកត់ត្រាជាចំណូលក្នុងឆ្នាំបន្ទាប់តែម្តង។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. កត់ត្រាចំណាយប្រាក់ខែ នៅថ្ងៃ៣០ ខែឧសភា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី បៀវត្សមូលដ្ឋាន | ៦៤០២១ | ២ ៥០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ២ ៥០០ ០០០ ០០០ |
| **ទី២. កត់ត្រាពេលមានសំណោសចំណាយក្នុងខែមករា ឆ្នាំ២០X១** | | |
| ឥណពន្ធ គណនី ធនាគារ | ១១.... | ២០ ០០០ ០០០ |
| ឥណទាន គណនី ផលហិរញ្ញវត្ថុផ្សេងទៀត | ៧៦៩៨១ | ២០ ០០០ ០០០ |

**បញ្ជាក់៖លេខនាគណនេយ្យខាងលើនេះ ពុំបានបង្ហាញគណនីចម្លងបណ្តោះអាសន្នទេ។**

**៧. ការបង្វិលសងប្រាក់ពន្ធលើតម្លៃបន្ថែម**

**ឧទាហរណ៍៖ ការបង្វិលសងប្រាក់ពន្ធលើតម្លៃបន្ថែមក្នុងឆ្នាំ**

ក្រុមហ៊ុន ABC investment co. គឺជាសហគ្រាសធនមធ្យមដែលនាំចេញទំនិញនិងសេវាកម្ម។ នៅខែឧសភា ឆ្នាំ២០X០ ក្រុមហ៊ុននេះមានចំនួនឥណទានពន្ធលើតម្លៃបន្ថែមលើធាតុចូលនៃចំនួន២ ៥០០ ០០០ ០០០រៀល ដែលត្រូវស្នើសុំការបង្វិលសងជាសាច់ប្រាក់វិញ។ ក្រុមហ៊ុន ABC investment co បានដាក់សំណើសុំបង្វិលសងប្រាក់ពន្ធលើតម្លៃបន្ថែមទៅអគ្គនាយកដ្ឋានពន្ធដារ។ បន្ទាប់ពីបានពិនិត្យនិងធ្វើសវនកម្មរួចរាល់ អគ្គនាយកដ្ឋានពន្ធដារនឹងស្នើសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាចុងក្រោយនៅពេលទទួលបានការអនុម័តយល់ព្រមរួចរាល់ អគ្គនាយកដ្ឋានពន្ធដារ នឹងចេញលិខិតឆ្លើយតបទៅអ្នកស្នើសុំវិញដោយភ្ជាប់ជាមួយនឹងការផ្ទេរប្រាក់បង្វិលសងតាមប្រព័ន្ធអេឡិចត្រូនិចនៅខែកក្កដា ឆ្នាំ២០X០។

កិច្ចបញ្ជិកាគណនេយ្យ

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. ពេលទទួលបានការអនុម័តពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខែកក្កដា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី ការបង្វិលសងវិញនូវពន្ធនិងអាករ | ៧០០៩១ | ២ ៥០០ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ២ ៥០០ ០០០ ០០០ |
| **ទី២. ពេលទូទាត់សាច់ប្រាក់ក្នុង ខែកក្កដា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ២ ៥០០ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ២ ៥០០ ០០០ ០០០ |

៨. **ការកែតម្រូវក្រោយពីការទទួលស្គាល់ចំណាយ** ក្នុងករណីមានតម្រូវការចាំបាច់ក្នុងការកែតម្រូវប្រតិបត្តិការដែលបានទទួលស្គាល់ពីមុន ស្ថាប័នសាធារណៈត្រូវគោរពតាមលក្ខខណ្ឌដូចមានកំណត់ក្នុងស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ លេខ១៤ ស្តីពីព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍។

## ជំពូកទី៥

## ការឈប់ទទួលស្គាល់គណនីត្រូវសង

គណនីត្រូវសងគឺជាតួលេខដែលត្រូវទូទាត់សងទៅឱ្យម្ចាស់បំណុល ឬ អង្គភាពដទៃផ្សេងទៀតសម្រាប់ទូទាត់ថ្លៃសេវា ឬ ទំនិញ ឬ កាតព្វកិច្ចដែលមិនទាន់ទូទាត់។ គណនីត្រូវសង ជា ធាតុមួយនៃបំណុលរយៈពេលខ្លី នៃរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ។ គណនីត្រូវសង មិនអាចត្រូវបានលុបចេញដោយសារតែជាបំណុលដែលហួសកាលកំណត់ត្រូវសងនោះទេ។ បំណុលអាចលុបចោល ឬ ដកចេញពីរបាយការណ៍ហិរញ្ញវត្ថុបាន លុះត្រាតែរាជរដ្ឋាភិបាលលែងមានកាតព្វកិច្ចក្នុងការសងបំណុលប៉ុណ្ណោះ។ ជាទូទៅ គណនីត្រូវសង ត្រូវបានកាត់កងនៅពេលដែលបំណុលត្រូវបានទូទាត់គ្រប់ចំនួន និងចប់សព្វគ្រប់។ ក្នុងករណីខ្លះ គណនីត្រូវសងត្រូវបានចាត់ទុកថាមិនអាចអនុវត្ត ដោយផ្អែកលើនីតិវិធីក្នុងកិច្ចសន្យា ឬ ច្បាប់ ដោយសារតែលក្ខខណ្ឌក្នុងកិច្ចសន្យាមិនត្រូវបានអនុវត្ត ឬ ដោយសារភាគីអ្នកផ្គត់ផ្គង់មិនមានបំណងបន្តផ្តល់សេវា ឬ ផ្គត់ផ្គង់ដូចដែលបានចែងក្នុងកិច្ចព្រមព្រៀង និងដោយមានការបញ្ជាក់ពីអាណាប័ក។

### ១. លក្ខខណ្ឌនៃការឈប់ទទួលស្គាល់គណនីត្រូវសង

ស្ថាប័នសាធារណៈ ត្រូវឈប់ទទួលស្គាល់គណនីត្រូវសងពីបញ្ជីគណនេយ្យក្នុងករណីដូចខាងក្រោម÷

ក. កាតព្វកិច្ចក្នុងការសងបំណុលលែងមាន នៅពេលដែលបំណុលត្រូវបានទូទាត់គ្រប់ចំនួន និងចប់សព្វគ្រប់ ឬ

ខ. កាតព្វកិច្ចក្នុងការសងបំណុលលែងមានតាមរយៈកិច្ចសន្យា និងច្បាប់ ដោយសារលក្ខខណ្ឌក្នុងកិច្ចសន្យាមិនត្រូវបានអនុវត្ត ឬ ដែលអនុញ្ញាតឱ្យកូនបំណុលមានជម្រើសក្នុងការបដិសេធសងបំណុលផ្នែកខ្លះ ឬ បំណុលទាំងស្រុងតែម្តង។

### ២. គណនេយ្យកម្មនៃការឈប់ទទួលស្គាល់គណនីត្រូវសង

**ឧទាហរណ៍ទី១÷ ការឈប់ទទួលស្គាល់គណនីត្រូវសង**

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០X០ ក្រសួង ក. បានទិញ និងទទួលសម្ភារការិយាល័យ ពីហាង ABC ចំនួន៤ ០០០ ០០០រៀល ជាមួយនឹងលក្ខខណ្ឌនៃការបង់ប្រាក់ដែលត្រូវធ្វើឡើងក្នុងរយៈពេលពីរសប្តាហ៍បន្ទាប់ពីទទួលបានទំនិញ។ ក្រសួង ក. ទូទាត់សាច់ប្រាក់ជូននៅសប្តាហ៍ដំបូងនៃខែតុលា ឆ្នាំ២០X០។ ក្នុងករណីនេះបំណុលត្រូវបានលុបចេញបន្ទាប់ពីសាច់ប្រាក់ត្រូវបានទូទាត់រួចរាល់។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. ពេលទទួលបានទំនិញថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី សម្ភារការិយាល័យ | ៦០០២១ | ៤ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤ ០០០ ០០០ |
| **ទី២. ពេលទូទាត់សាច់ប្រាក់បានទំនិញថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤ ០០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ៤ ០០០ ០០០ |

**ឧទាហរណ៍ទី២÷ ការឈប់ទទួលស្គាល់គណនីត្រូវសងតាមរយៈការដោះដូរទ្រព្យ**

ស្ថាប័នសាធារណៈសម្រេចដោះដូរដីរដ្ឋបាល ជាមួយក្រុមហ៊ុនឯកជន ឈ្មោះ ABC Co., Ltd.។ ដីរបស់ស្ថាប័នសាធារណៈមានតម្លៃ៤០០ ០០០ លានរៀល ដែលនឹងត្រូវដោះដូរជាមួយដីឯកជនមានតម្លៃ១០០ ០០០លានរៀល បូកនឹងអគាររដ្ឋបាលថ្មីមានតម្លៃ៣០០ ០០០លានរៀល ដែលត្រូវចេញលុយសាងសង់ដោយក្រុមហ៊ុន ABC។ ដីរបស់ស្ថាប័នសាធារណៈនឹងត្រូវប្រគល់ទៅឱ្យក្រុមហ៊ុន ABC Co., Ltd ក្នុងរយៈពេលមួយខែ បន្ទាប់ពីអគាររដ្ឋបាលថ្មីនេះសាងសង់រួច និងប្រគល់ជូនរដ្ឋ។ ក្នុងករណីនេះបំណុលត្រូវបានលុបចេញ បន្ទាប់ពីស្ថាប័នសាធារណៈប្រគល់ដីជូនក្រុមហ៊ុន ABC។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. ពេលទទួលបានដី និងអគាររដ្ឋបាលពីក្រុមហ៊ុន ABC** | | |
| ឥណពន្ធ គណនី ដីធ្លី | ២១០១១ | ១០០ ០០០ ០០០ ០០០ |
| ឥណពន្ធ គណនី សំណង់អាគារ | ២១០៣១ | ៣០០ ០០០ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤០០ ០០០ ០០០ ០០០ |
| **ទី២. ពេលប្រគល់ដីជូនក្រុមហ៊ុន ABC** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤០០ ០០០ ០០០ ០០០ |
| ឥណទាន គណនី ដីធ្លី | ២១០១១ | ៤០០ ០០០ ០០០ ០០០ |

**ឧទាហរណ៍ទី៣÷ ការឈប់ទទួលស្គាល់គណនីត្រូវសងដោយមិនបន្តផ្គត់ផ្គង់**

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០X០ ក្រសួង ក. បានទិញ និងទទួលសម្ភារការិយាល័យ ពីហាង ABC ចំនួន៤ ០០០ ០០០រៀល ជាមួយនឹងលក្ខខណ្ឌនៃការបង់ប្រាក់ដែលត្រូវធ្វើឡើងក្នុងរយៈពេលពីរសប្តាហ៍ បន្ទាប់ពីទទួលបានទំនិញ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីទទួលបានទំនិញមួយសប្តាហ៍ក្រោយមក មានសម្ភារការិយាល័យមួយចំនួន ត្រូវបានពិនិត្យឃើញថាមិនមានគុណភាព និងមិនអាចយកមកប្រើការបានមានតម្លៃ៤០០ ០០០រៀល។ ក្រសួង ក. បានប្រាប់ក្រុមហ៊ុន ABC អំពីឧប្បត្តិហេតុនេះ និងយល់ព្រមកាត់បន្ថយតម្លៃទំនិញដែលខូចខាតនោះចំនួន៤០០ ០០០រៀល ដោយសារតែក្រុមហ៊ុន ABC មិនមានស្តុកទំនិញមកដូរ។ ក្រសួង ក. ទូទាត់សាច់ប្រាក់ជូននៅសប្តាហ៍ដំបូងនៃខែតុលា ២០X០។ ក្នុងករណីនេះបំណុលត្រូវបានលុបចេញ បន្ទាប់ពីអ្នកផ្គត់ផ្គង់មិនមានស្តុកទំនិញថ្មីយកមកដូរ។

**កិច្ចបញ្ជិកាគណនេយ្យ**

| | មាតិកាគណនី | ចំនួនជារៀល |
|---|---|---|
| **ទី១. ពេលទទួលបានទំនិញថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី សម្ភារការិយាល័យ | ៦០០២១ | ៤ ០០០ ០០០ |
| ឥណទាន គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤ ០០០ ០០០ |
| **ទី២. ពេលយល់ព្រមកាត់បន្ថយតម្លៃទំនិញដែលខូចខាតនោះចំនួន៤០០ ០០០រៀល** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៤០០ ០០០ |

| | | |
|---|---|---|
| ឥណទាន គណនី សម្ភារការិយាល័យ | ៦០០២១ | ៤០០ ០០០ |
| **ទី៣. ពេលទូទាត់សាច់ប្រាក់បានទំនិញសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០X០** | | |
| ឥណពន្ធ គណនី អ្នកផ្គត់ផ្គង់ | ៤០០១ | ៣ ៦០០ ០០០ |
| ឥណទាន គណនី ធនាគារ | ១១.... | ៣ ៦០០ ០០០ |

## ជំពូកទី៦

## វិធីបដំណើរការនិងការរាយការណ៍នៃគណនីត្រូវសង

ជំពូកនេះបង្ហាញភាគីពាក់ព័ន្ធសំខាន់ៗ វិធីបដំណើរការ និង ឯកសារតម្រូវសម្រាប់ការទទួលស្គាល់ចំណាយ ការកត់ត្រា និងការរាយការណ៍នៃគណនីត្រូវសង។

**១.ភាគីពាក់ព័ន្ធ**

ភាគីពាក់ព័ន្ធនៅក្នុងកិច្ចបញ្ជិកាគណនេយ្យនៃចំណាយ និងចំណាយបង្គររួមមាន÷

ក. អាណាប័ក សំដៅដល់អ្នកមានសិទ្ធិអំណាចគ្រប់គ្រាន់តាមច្បាប់ក្នុងការបញ្ជាកិច្ចប្រតិបត្តិការចំណូលនិងចំណាយថវិការបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងវង្វង់ឥណទានថវិការបស់ខ្លួន។

ខ. អ្នកត្រួតពិនិត្យថវិកា សំដៅដល់អង្គភាពត្រួតពិនិត្យថវិកាសម្រាប់ថវិកាថ្នាក់ជាតិ ដូចមានចែងក្នុងមាត្រា៧៥នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បំពេញមុខងារជាសេនាធិការលើការត្រួតពិនិត្យការអនុវត្តថវិកា។

គ. គណនេយ្យករសាធារណៈ សំដៅដល់ភ្នាក់ងាររបស់រដ្ឋ ដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋ។ គណនេយ្យករសាធារណៈ រួមមានគណនេយ្យកររតនាគារ គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល គណនេយ្យករថវិកាឧបសម្ព័ន្ធ គណនេយ្យករគណនីពិសេសរតនាគារ និងគណនេយ្យករដែលអនុវត្តគណនេយ្យនៃថវិការដ្ឋដទៃទៀត។ គណនេយ្យកររតនាគារ រួមមាន គណនេយ្យកររតនាគារកណ្តាល និងគណនេយ្យកររតនាគាររាជធានី ខេត្ត។

ឃ. អ្នកផ្គត់ផ្គង់ ទាំងនិវាសនជន និងអនិវាសជន ដែលជាអ្នកមានកាតព្វកិច្ចផ្គត់ផ្គង់ទំនិញនិងសេវាកម្មដល់រាជរដ្ឋាភិបាល។ អ្នកផ្គត់ផ្គង់ ក៏រួមបញ្ចូលមន្រ្តីដែលបម្រើការនៅក្នុងរាជរដ្ឋាភិបាលផងដែរ។

ង. អ្នកទទួលផលផ្សេងទៀត សំដៅលើភាគីផ្សេងទៀតដែលទទួលផលពាក់ព័ន្ធនឹងអ្នកផ្គត់ផ្គង់

ច. និយ័តករគណនេយ្យនិងសវនកម្ម គឺជាស្ថាប័នដែលទទួលបន្ទុកលើការកំណត់ស្តង់ដានៃអភិបាលកិច្ច និងការអភិវឌ្ឍវិស័យគណនេយ្យ និងសវនកម្ម និងវិជ្ជាជីវៈនៅកម្ពុជាតាមរយៈការណែនាំអំពីបទដ្ឋាន ច្បាប់ និងបទប្បញ្ញត្តិនានា។

ឆ. អគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានភារកិច្ចអភិវឌ្ឍមុខងារនៅក្នុង FMIS ដើម្បីគាំទ្រដល់ការគ្រប់គ្រងគណនីត្រូវសង។

ជ. អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យ និងបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព ប្រតិបត្តិការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនាំមុខក្នុងការអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល។

ឈ. អាជ្ញាធរសវនកម្មជាតិ គឺជាស្ថាប័នសាធារណៈឯករាជ្យ និងរាយកាណ៍ដោយផ្ទាល់ជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលក្នុងគោលបំណងផ្តល់ព័ត៌មាន និងទទួលបន្ទុកក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុលើស្ថាប័នសាធារណៈ។

ញ. អគ្គាធិការដ្ឋាន គឺជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកក្នុងការធ្វើអធិការកិច្ច

ហិរញ្ញវត្ថុលើអនុលោមភាពនិងសមិទ្ធកម្មនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងគ្រប់គ្រងហានិភ័យ តាមអនុសាសន៍របស់រាជរដ្ឋាភិបាល ដៃគូរអភិវឌ្ឍ និងស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

**២.វិហ្វរដំណើរការ**

កិច្ចប្រតិបត្តិការចំណាយត្រូវអនុវត្តតាម៥(ប្រាំ)ដំណាក់កាល រួមមាន÷(១)-ការធានាចំណាយ (២)-ការអនុវត្តកិច្ចលទ្ធកម្ម (៣)-ការជម្រះបញ្ជីចំណាយ (៤)-អាណាប័ណ្ណ និង (៥)-ការទូទាត់ ដូចមានចែងក្នុងមាត្រានៃអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ។

**៣. ឯកសារតម្រូវសម្រាប់ការទទួលស្គាល់ចំណាយ**

ឯកសារតម្រូវសម្រាប់ការទទួលស្គាល់ចំណាយ រួមមាន÷

- វិក្កយបត្រ
- អាណត្តិទូទាត់
- សក្ខីបត្រ
- លិខិតប្រគល់ ទទួល
- កិច្ចសន្យា ឬ កិច្ចព្រមព្រៀង
- ឯកសារផ្សេងទៀតតាមការចាំបាច់។

**៤. សមតុល្យដើមគ្រានៃគណនីត្រូវសង**

ក្នុងគណនីសៀវភៅធំ គណនីត្រូវសង គឺជាគណនីបំណុលរយៈពេលខ្លី ដោយសារទឹកប្រាក់ដែលត្រូវសងជាធម្មតាមានរយៈពេលត្រូវទូទាត់ក្នុងកំឡុងពេល ១០ថ្ងៃ ឬ ៣០ថ្ងៃ ឬ ៦០ថ្ងៃ។ ល ។ ជាទូទៅ សមតុល្យនៃគណនីត្រូវសងត្រូវបានបង្ហាញជាធាតុទីមួយ ឬ ទីពីរនៅក្នុងផ្នែកខាងលើគេនៃបំណុលរយៈពេលខ្លី នៃតារាងតុល្យការ។

សមតុល្យនៃគណនីត្រូវសងដែលពុំទាន់បានទូទាត់នៅក្នុងឆ្នាំការិយបរិច្ឆេទ ត្រូវយោងបន្តទៅក្នុងការិយបរិច្ឆេទឆ្នាំបន្ទាប់។

គណនីត្រូវសង ត្រូវបានតាមដាននិងទូទាត់ឱ្យបានឆាប់រហ័ស(មិនឱ្យលើសពី ៦០ ថ្ងៃ បន្ទាប់ពីគណនេយ្យករសាធារណៈទទួលបានការស្នើសុំទូទាត់) ដើម្បីជៀសវាងបញ្ហាបំណុលកកស្ទះ។

**៥. ការរាយការណ៍គណនីត្រូវសង**

គណនេយ្យករសាធារណៈ គឺជាអ្នកទទួលបន្ទុកក្នុងការរាយការណ៍អំពីស្ថានភាពនៃគណនីត្រូវទទួលដែលពាក់ព័ន្ធនឹងចំណាយ និងត្រូវផ្ញើរបាយការណ៍នោះជូនស្ថាប័នសាធារណៈ ដើម្បីពិនិត្យនិងឯកភាពលើភាពត្រឹមត្រូវនៃគណនីត្រូវសង។ ក្នុងករណីដែលពិនិត្យឃើញថាត្រឹមត្រូវហើយ ស្ថាប័នសាធារណៈ ត្រូវចុះហត្ថលេខាទទួលស្គាល់លើរបាយការណ៍នោះនិងផ្ញើជូនគណនេយ្យករសាធារណៈវិញដើម្បីមុខការបន្ត។ គណនេយ្យករសាធារណៈត្រូវរៀបចំរបាយការណ៍ស្តីពីស្ថានភាពរួមគណនីត្រូវសងដែលមានទម្រង់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៣ នៃគោលការណ៍ណែនាំនេះ។

ក្នុងករណីដែលពិនិត្យឃើញថាពុំទាន់មានភាពត្រឹមត្រូវ ស្ថាប័នសាធារណៈ ត្រូវបញ្ជូនរបាយការណ៍ស្តីពីស្ថានភាពគណនីត្រូវសងទៅគណនេយ្យករសាធារណៈវិញ ដើម្បីពិនិត្យនិងកែតម្រូវ។

របាយការណ៍ស្តីពីស្ថានភាពនៃគណនីត្រូវទទួលដែលមានទម្រង់ដូចមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ២ នៃគោលការណ៍ណែនាំនេះ ត្រូវបញ្ជូនមកគណនេយ្យករសាធារណៈ យ៉ាងយូរត្រឹមថ្ងៃទី២៨ ខែកុម្ភៈ នៃឆ្នាំបន្ទាប់។

## ឧបសម្ព័ន្ធ១៖ ការផ្គូផ្គងចំណាយជាមួយនឹងលក្ខខណ្ឌតម្រូវនៃស្តង់ដាគណនេយ្យសាធារណៈកម្ពុជានិងអន្តរជាតិ

| ប្រភេទចំណាយ<br>តាមលិខិតបទដ្ឋានគតិយុត្តជាធរមាន | មាតិកា<br>ចំណាយថវិកា | ប្រភេទចំណាយ<br>តាមស្តង់ដាគណនេយ្យសាធារណៈ<br>កម្ពុជានិងអន្តរជាតិ | លក្ខខណ្ឌនិងពេលវេលានៃការទទួលស្គាល់ |
|---|---|---|---|
| **១. ចំណាយបន្ទុកបុគ្គលិក** | 64 | - ស្តង់ដាលេខ៣៩ ស្តីពី អត្ថប្រយោជន៍បុគ្គលិក | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២.១.១ នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ក. នៅពេលដែលបុគ្គលិកបានផ្តល់សេវា ដើម្បីទទួលបានអត្ថប្រយោជន៍ដែលនឹងត្រូវផ្តល់ជូនបុគ្គលិកនៅពេលអនាគត និង<br>ខ. នៅពេលដែលស្ថាប័នសាធារណៈទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សក្តានុពលសេវាកម្មដែលអាចកើត មានឡើងពីការផ្តល់សេវារបស់មន្ត្រីបុគ្គលិក។ |
| លាភការ និងប្រាក់បំណាច់នៃអំណាចសាធារណៈ | 6401 | | |
| លាភការនិងប្រាក់បំណាច់ បុគ្គលិកក្របខ័ណ្ឌអចិន្ត្រៃយ៍ | 6402 | | |
| ប្រាក់បំណាច់ផ្សេងៗ | 6403 | | |
| លាភការ និងប្រាក់បំណាច់បុគ្គលិកមិនមែនក្របខ័ណ្ឌ | 6404 | | |
| ប្រាក់វិភាជន៍សង្គមសម្រាប់មន្ត្រីរាជការ និងបុគ្គលិកផ្សេងៗ | 6405 | | |
| ប្រាក់វិភាជន៍សង្គមសម្រាប់គ្រួសារមន្ត្រីរាជការ | 6406 | | |
| លាភការ និងប្រាក់បំណាច់នៃអំណាចរដ្ឋបាលថ្នាក់ក្រោមជាតិ | 6407 | | |
| បន្ទុកបុគ្គលិកផ្សេងៗទៀត | 6498 | | |
| **២. ចំណាយពីការទិញទំនិញ និងសេវាកម្ម** | 60<br>61 | - ស្តង់ដាលេខ១ ស្តីពីការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២.១.២. នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ក. ទទួលបានទំនិញ ឬ សេវាកម្ម ណាមួយដោយផ្ទាល់ពីអ្នកផ្គត់ផ្គង់ជាថ្នូរ ដែលជាករណីមានការទិញ/ លក់។ និង<br>ខ.ពាក់ព័ន្ធនឹងការព្រមព្រៀងបង់ប្រាក់ជាមួយស្ថាប័ន |
| សម្ភារផ្គត់ផ្គង់ថែទាំ | 6001 | | |
| សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល | 6002 | | |
| ស្បៀងអាហារ និងផលិតផលកសិកម្ម | 6003 | | |
| សំលៀកបំពាក់ និងការតុបតែង | 6004 | | |
| សម្ភារតូចតាច សង្ហារិម និងសម្ភារបរិក្ខារ | 6005 | | |

| | | | |
|---|---|---|---|
| ថាមពលនិងទឹក | 6006 | | ផ្សេងទៀត ការទទួលស្គាល់ចំណាយនៅពេលកិច្ចព្រមព្រៀងជាផ្លូវការ ត្រូវបានចុះហត្ថលេខា និងបានកំណត់ចំនួនទឹកប្រាក់ជាក់លាក់។ |
| សម្ភារបរិក្ខារថែទាំសុខភាព | 6007 | | |
| សម្ភារផ្គត់ផ្គង់ផ្សេងៗ | 6098 | | |
| បម្រែបម្រួលសន្និធិ | 6099 | | |
| កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស | 6101 | | |
| ការជួលមធ្យោបាយដឹកជញ្ជូន | 6102 | | |
| ថ្លៃឈ្នួល និងបន្ទុក(អសង្ហារិម) ក្នុងនិងក្រៅប្រទេស | 6103 | | |
| សោហ៊ុយបណ្តុះបណ្តាល ក្នុងនិងក្រៅប្រទេស | 6104 | | |
| ការថែទាំនិងជួសជុល | 6105 | | |
| សោហ៊ុយធានារ៉ាប់រង | 6106 | | |
| សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ និងសំណងផ្សេងៗ | 6107 | | |
| សោហ៊ុយដឹកជញ្ជូន | 6108 | | |
| បុគ្គលិកខាងក្រៅ | 6109 | | |
| ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | 6110 | | |
| សារព័ត៌មាន និងឯកសារ | 6111 | | |
| សោហ៊ុយបេសកកម្មក្នុងប្រទេស | 6112 | | |
| សោហ៊ុយបេសកកម្មក្រៅប្រទេស | 6113 | | |
| សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | 6114 | | |
| សោហ៊ុយធនាគារ | 6115 | | |
| សំណងកិច្ចសន្យា | 6116 | | |

| | | | |
|---|---|---|---|
| សេវាកម្មផ្សេងៗទៀត | 6198 | | |
| **៣. បន្ទុកហិរញ្ញវត្ថុ** | 66 | -ស្តង់ដាលេខ៥ ស្តីពីបន្ទុកលើប្រាក់កម្ចី | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២.១.៤. នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ក. ចំណាយពីការខ្ចីប្រាក់ ត្រូវទទួលស្គាល់ជាចំណាយនៅពេលដែលការខ្ចីកើតឡើង<br>ខ. ការកំណត់តាមស្តង់ដា ចំណាយពីការប្រាក់កម្ចីត្រូវបានទទួលស្គាល់ជាចំណាយ ទៅតាមរយៈពេលដែលការខ្ចីកើតឡើង។ |
| ការប្រាក់នៃបំណុលក្នុងប្រទេស | 6601 | | |
| ការប្រាក់នៃបំណុលក្រៅប្រទេស | 6602 | | |
| បន្ទុកហិរញ្ញវត្ថុផ្សេងៗទៀត | 6698 | | |
| **៤. ចំណាយមូលធន (រំលស់)** | **យោងតាមប្រកាសលេខ ៣៩៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យនៃទ្រព្យសកម្មរយៈពេលវែង។** | - ស្តង់ដាលេខ១៧ ស្តីពីទ្រព្យសម្បត្តិរោងចក្រ និងគ្រឿងបរិក្ខារ | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២.១.៣ នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ក. ទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ច ឬ សេវាកម្មនាពេលអនាគតដែលពាក់ព័ន្ធនឹងទ្រព្យនោះនឹងហូរចូលអង្គភាព<br>ខ. ស្ថាប័នសាធារណៈមានសិទ្ធិលើការគ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិ<br>គ. តម្លៃសមស្របនៃទ្រព្យអាចធ្វើការវាស់វែងបាន |

| | | | |
|---|---|---|---|
| **៥. ចំណាយពីការផ្ទេរ** | | - ស្តង់ដាលេខ២៣ ស្តីពីចំណូលពីប្រតិបត្តិការមិនដោះដូរ (ការផ្ទេរ) | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២.១.១. នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>ចំណាយត្រូវទទួលស្គាល់ នៅពេលចុះហត្ថលេខាពីការផ្តល់ជំនួយសាច់ប្រាក់។ |
| **ឧបត្ថម្ភធន** | 65 | | |
| ឧបត្ថម្ភធនរវាងរដ្ឋបាលសាធារណៈ | 6501 | | |
| ឧបត្ថម្ភធនដល់អង្គការសាធារណៈ | 6502 | | |
| ឧបត្ថម្ភធនដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល | 6503 | | |
| ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ | 6504 | | |
| ឧបត្ថម្ភធនដល់សហគ្រាសឯកជន | 6505 | | |
| វិភាគទានដល់អង្គការ សមាគម សហព័ន្ធអន្តរជាតិនានា | 6506 | | |
| ការចូលរួមក្នុងការអនុវត្តគំរោង | 6507 | | |
| ឧបត្ថម្ភអង្គការអន្តរជាតិ និងប្រទេសផ្សេងៗ | 6508 | | |
| ការបង្វិលសងវិញនូវឧបត្ថម្ភធនពីក្រៅប្រទេសសម្រាប់ចំណាយវិនិយោគ | 6509 | | |
| ឧបត្ថម្ភធនផ្សេងៗ | 6598 | | |
| **អត្ថប្រយោជន៍សង្គម** | 62 | | |
| អត្ថប្រយោជន៍របបសន្តិសុខសង្គម | 6201 | | |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 6202 | | |
| ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌ | 6203 | | |
| ឧបត្ថម្ភដល់អង្គការមូលដ្ឋាន និងគាំទ្រកម្មវិធីផ្សេងៗ | 6204 | | |
| ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច | 6205 | | |
| ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌ | 6206 | | |
| ឧបត្ថម្ភលើតាវកាលិក | 6207 | | |
| អត្ថប្រយោជន៍សង្គមផ្សេងទៀត | 6298 | | |

| | | | |
|---|---|---|---|
| **៥. ចំណាយផ្សេងៗ (ពន្ធបន្ទុករបស់រដ្ឋ)** | **63,70** | - ស្តង់ដាលេខ១ ស្តីពីការដាក់បង្ហាញរបាយការណ៍ហិរញ្ញវត្ថុ | **១. លក្ខខណ្ឌនៃការទទួលស្គាល់**<br>- ចំណុច ២.១.២ នៃជំពូកទី២។<br>**២. ពេលវេលានៃការទទួលស្គាល់**<br>- ចំណាយបន្ទុកត្រូវទទួលស្គាល់នៅពេលបន្ទុកចំណាយត្រូវបានបង្កើត។ |
| លតាប័ត្រ | **6301** | | |
| បន្ទុកពន្ធគយលើការនាំចូលទំនិញ និងសម្ភារ | **6302** | | |
| បន្ទុកពន្ធប្រថាប់ត្រា | **6303** | | |
| បន្ទុកពន្ធលើផលទុននៃដីធ្លី ផ្ទះសម្បែង | **6304** | | |
| អាករលើតម្លៃបន្ថែមលើទំនិញ និងសេវាជាបន្ទុករបស់រដ្ឋ | **6305** | | |
| ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ពន្ធលើអចលនទ្រព្យ និងពន្ធលើប្រាក់ចំណូល | **6306** | | |
| ពន្ធនិងអាករផ្សេងៗ | **6398** | | |
| ការបង្វិលសងវិញនូវពន្ធនិងអាករផ្សេងៗ | **7009** | | |

**ឧបសម្ព័ន្ធ២÷ គំរូរបាយការណ៍នៃគណនីត្រូវសង**

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

{Logo}
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានរតនាគាររជាតិ
លេខ...................................

## របាយការណ៍ស្តីពីស្ថានភាពគណនីត្រូវសង
## របស់(ឈ្មោះស្ថាប័នសាធារណៈ)

ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២0XX

ថ្ងៃ...........ខែ...........ឆ្នាំ.......... ស័ក ព.ស..............
ធ្វើនៅ...............ថ្ងៃទី............ខែ.......ឆ្នាំ.............

ឯកតា÷រៀល

| ល.រ. | គណនីត្រូវសង តាមប្រភេទចំណាយ | សមតុល្យដើមគ្រា | គណនីត្រូវសង ដែលបានកើតឡើងក្នុងឆ្នាំ | គណនីត្រូវសង ដែលបានទូទាត់ក្នុងឆ្នាំ | គណនីត្រូវសង ដែលបានលុបចេញក្នុងឆ្នាំ | ការកែតម្រូវ | សមតុល្យចុងគ្រា |
|---|---|---|---|---|---|---|---|
| | | 1 | 2 | 3 | 4 | 5 | 6=1+2-3-4(-/+)5 |
| ១ | ចំណាយបន្ទុកបុគ្គលិក | | | | | | |
| ២ | ចំណាយពីការទិញទំនិញ និងសេវាកម្ម | | | | | | |
| ៣ | ចំណាយមូលធន | | | | | | |
| ៤ | ចំណាយពីការខ្ចីប្រាក់ | | | | | | |
| ៥ | ចំណាយពីការផ្ទេរ | | | | | | |
| | សរុបរួម | | | | | | |

កំណត់សម្គាល់÷ សូមពន្យល់អំពីមូលហេតុ ឬព្រឹត្តិការណ៍នានាដែលនាំឱ្យមានការប្រែប្រួលតួលេខគណនីត្រូវសង។

ប្រធានស្ថាប័នសាធារណៈ

គណនេយ្យករសាធារណៈ

ឧបសម្ព័ន្ធ៣៖ គំរូរបាយការណ៍រួមនៃគណនីត្រូវសង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍សរុបរួមស្តីពីស្ថានភាពគណនីត្រូវសង

របស់រាជរដ្ឋាភិបាលកម្ពុជា

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២0XX

{Logo}

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរតនាគារជាតិ

លេខ.................................

ឯកតា÷រៀល

| ល.រ. | ប្រភេទគណនីត្រូវទទួល | កំណត់សម្គាល់ | ឆ្នាំសារពើពន្ធ N | ឆ្នាំសារពើពន្ធ N-1 |
|---|---|---|---|---|
| ១. | គណនីត្រូវសង(ថ្នាក់កណ្តាល) | (...) | | |
| ២. | គណនីត្រូវសង(រាជធានី ខេត្ត) | (...) | | |
| | **សរុបគណនីត្រូវសង** | | | |

កំណត់សម្គាល់÷

នាយកដ្ឋានគណនេយ្យ ត្រូវពន្យល់អំពីមូលហេតុ ឬព្រឹត្តិការណ៍នានាដែលនាំឱ្យមានការប្រែប្រួលតួលេខគណនីត្រូវសងក្នុងឆ្នាំ។

**បានឃើញ និងឯកភាព**

ថ្ងៃ...........ខែ..........ឆ្នាំ......... ស័ក ព.ស..............

ធ្វើនៅ...............ថ្ងៃទី............ខែ.......ឆ្នាំ..............

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**ប្រធាន**

**នាយកដ្ឋានគណនេយ្យ**

**ប្រធាន**

**ការិយាល័យគណនេយ្យទី១ និងសរុបរួម**

ថ្ងៃ...........ខែ..........ឆ្នាំ......... ស័ក ព.ស..............

ធ្វើនៅ...............ថ្ងៃទី............ខែ.......ឆ្នាំ..............

**អ្នករៀបចំ**